សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ន្ធ

សរសេរសារណាពីថ្ងៃទី ០២ ខែ មិថុនា ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៥


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ឡាយ ហុងគេក**
**សាង គឹមឈៀង**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ឃឹម ម៉ាណែត**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ
ជំនាន់ទី១៥

ឆ្នាំចូលសិក្សា ២០១១
ឆ្នាំសរសេររបាយការណ៍២០១៥

# អារម្ភកថា

ជាទូទៅក្នុងសង្គមនីមួយៗ មនុស្សគ្រប់រូបត្រូវទទួលបានសិទ្ធិស្មើៗគ្នាតាមផ្លូវច្បាប់ក្នុងការធ្វើសកម្មភាពអ្វីមួយ។ ក្នុងការទទួលបាននូវសិទ្ធិនេះ ប្រជាជនគប្បីយល់ដឹងនូវទំហំនៃសិទ្ធិដែលខ្លួនមានតាមរយៈច្បាប់នេះ។ ក៏ប៉ុន្តែ ប្រសិនបើយើងក្រឡេកទៅមើលប្រទេសដែលកំពុងអភិវឌ្ឍមួយចំនួនចំណេះដឹងរបស់ប្រជាពលរដ្ឋដែលទាក់ទងទៅនឹងវិស័យច្បាប់ គឺនៅមានកម្រិតនៅឡើយ ដែលជាហេតុនាំឲ្យមានការរំលោភបំពានសិទ្ធិនេះពីសំណាក់ជនខិលខូចមួយចំនួន។

ដូច្នេះដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយពីការរំលោភបំពានលើសិទ្ធិនេះ យើងខ្ញុំជានិស្សិតនៃសកលវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានទទួលនូវភារកិច្ចក្នុងការសរសេរនូវសារណាបញ្ចប់ឆ្នាំសិក្សានេះ បានធ្វើការជ្រើសរើសនូវប្រធានបទមួយដែលមានចំណងថា **ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ** យកមកធ្វើការស្វែងយល់អំពីសិទ្ធិ និង កាតព្វកិច្ចរបស់សហព័ទ្ធក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិគ្រួសារ។

ចំពោះសកម្មភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធនៅកម្ពុជាយើង មានការប្រែប្រួលពីមួយជំនាន់ទៅមួយជំនាន់ រហូតដល់ថ្ងៃ ០៨ ខែធ្នូ ឆ្នាំ ២០០៧ ក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការ ដែលក្រមនេះក៏បានចែងពីគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធផងដែរ។ ការអនុវត្តគោលការណ៍នេះក៏ទទួលបាននូវភាពប្រសើររហូតមកដល់បច្ចុប្បន្ន ។

ដូច្នេះយើងខ្ញុំជឿជាក់ថា កម្រងសារណារបស់យើងខ្ញុំនឹងចូលរួមចំណែកមួយផ្នែកក្នុងការផ្តល់នូវចំណេះដឹងលើការគ្រប់គ្រងទ្រព្យសម្បត្តិនេះជូនប្រជាពលរដ្ឋ ដើម្បីយកទៅអនុវត្តក្នុងសង្គមក៏ដូចជាសិស្សានុសិស្សជំនាន់ក្រោយៗក្នុងការស្វែងយល់ពីបញ្ហានេះ។ ស្របគ្នានេះដែរ យើងខ្ញុំក៏សូមអភ័យទោសចំពោះកំហុសដោយអចេតនាលើផ្នែកណាមួយ ឬក៏ឃ្លាណាមួយ។ យើងខ្ញុំរង់ចាំដោយក្តីសោមនស្សរីករាយចំពោះការរិះគន់ដើម្បីស្ថាបនារបស់លោក លោកស្រី និងប្រិយមិត្តដែលបានអាននូវសៀវភៅនេះ។

យើងខ្ញុំមានតែប្រាមដៃដប់ក្នុងការគោរពអរគុណដល់អស់លោក លោកស្រី និង ប្រិយមិត្តអ្នកអាន ដែលចំណាយពេលវេលាក៏មានតម្លៃក្នុងការអាន និងស្វែងយល់ ស្នាដៃរបស់យើងខ្ញុំ។

# សេចក្ដីថ្លែងអំណរគុណ

សូមសម្ដែងការគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ លោកឪពុកអ្នកម្ដាយដែលបានផ្ដល់ជីវិត ចិញ្ចឹមបីបាច់ថែរក្សា និងបានផ្ដល់នូវសេចក្ដីស្រឡាញ់ មេត្តា ករុណា អប់រំទូន្មានកូនឲ្យមានសេចក្ដីព្យាយាមក្នុងជីវិត។ ព្រមទាំងសូមអរគុណអ្នកមានគុណទាំងពីរ ដែលបានធ្វើពលិកម្មគ្រប់យ៉ាងសម្រាប់ការសិក្សារបស់កូនទទួលបាននូវចំណេះដឹងដ៏ថ្លៃថ្លា ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ ឯកឧត្ដមសាកលវិទ្យាធិការ **លុយ ចណ្ណា** និងសាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានលះបង់នូវកម្លាំងកាយចិត្ត ក្នុងការដឹកនាំបង្ហាត់បង្រៀន ក៏ដូចជាផ្ដល់នូវចំណេះដឹង និងដំបូន្មានល្អៗដល់យើងខ្ញុំ។ ដោយសារតែគុណូបការៈរបស់លោកនេះហើយទើបធ្វើឲ្យយើងខ្ញុំបានទទួលយកចំណេះដឹងនេះរហូតដល់អាចបញ្ចប់ការសិក្សាដោយជោគជ័យ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកស្រីសាស្ត្រាចារ្យ **ឃឹម ម៉ាណែត** ជាសាស្ត្រាចារ្យណែនាំ ដែលលោកស្រីបានចំណាយពេលវេលាដ៏មានតម្លៃ លះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីជួយណែនាំផ្ដល់នូវដំបូន្មាន កែសម្រួល និងតម្រង់ទិសយើងខ្ញុំរហូតដល់សារណានេះទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាកិច្ចបញ្ចប់ យើងខ្ញុំជូនពរដល់ ឯកឧត្ដម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានជួបតែសំណាងល្អ ទទួលបាននូវភាពជោគជ័យក្នុងជីវិត និងមានភាពសុខដុមរមនាក្នុងជីវិតជាសហព័ទ្ធរបស់ខ្លួន និងជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


សេចក្តីផ្តើម ........ ១

ជំពូកទី១ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា ........ ៣

ផ្នែកទី១ បទប្បញ្ញត្តិទូទៅនៃពាក្យសុំចុះបញ្ជី ........ ៥

១.១. ពាក្យសុំចុះបញ្ជី ........ ៥

១.១.១. លក្ខខណ្ឌគ្រឹះ ........ ៥

ក. ការព្រមព្រៀង ........ ៦

ខ. សមត្ថភាព ........ ៦

គ. កម្មវត្ថុ ........ ៩

១.១.២. លក្ខខណ្ឌទម្រង់ ........ ១០

ក. ទម្រង់បែបបទពាក្យសុំចុះបញ្ជី ........ ១១

ខ. ឯកសារភ្ជាប់ ........ ១២

១.២. នីតិវិធីនៃការចុះបញ្ជី ........ ១៣

១.២.១. ស្ថាប័នមានសមត្ថកិច្ច ........ ១៣

១.២.២. ការទទួលពាក្យសុំចុះបញ្ជី ........ ១៥

១.២.៣. របៀបចុះបញ្ជី ........ ១៧

១.២.៤. ការចេញលិខិតបញ្ជាក់ ........ ១៧

ផ្នែកទី២ ការកែប្រែ និង ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ១៩

២.១. ការផ្លាស់ប្តូរ ឬ កែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ១៩

២.១.១. ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ២០

២.១.២. ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ២១

២.២. ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ........ ២៣
២.២.១. ការរំលាយចំណងអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ ........ ២៤
២.២.២. មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ........ ២៦
២.២.៣. សេចក្ដីសម្រេចរបស់តុលាការ ........ ២៨
ជំពូកទី២ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់ ........ ២៩
ផ្នែកទី១ ប្រភេទនៃទ្រព្យសម្បត្តិ ........ ៣០
១.១. ទ្រព្យសម្បត្តិដោយឡែក ........ ៣០
១.១.១. លក្ខណៈបុគ្គលនៃទ្រព្យសម្បត្តិដោយឡែក ........ ៣១
១.១.២. ប្រភពនៃទ្រព្យសម្បត្តិដោយឡែក ........ ៣២
១.១.៣. ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដោយឡែក ........ ៣៣
១.២. ទ្រព្យសម្បត្តិរួម ........ ៣៤
១.២.១. ប្រភពនៃទ្រព្យរួម ........ ៣៤
១.២.២. ការគ្រប់គ្រងទ្រព្យសម្បត្តិរួម ........ ៣៥
១.២.៣. ការចាត់ចែងទ្រព្យសម្បត្តិរួម ........ ៣៦
ផ្នែកទី២ ការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យរបស់សហព័ន្ធតាមច្បាប់កំណត់ ........ ៣៧
២.១. មូលហេតុនៃការបញ្ចប់ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិសហព័ទ្ធ ........ ៣៧
២.១.១. ការលែងលះ ........ ៣៨
២.១.២. មរណភាព និងការបាត់ខ្លួន ........ ៤០
២.១.៣. មោឃភាព និងការលុបចោលអពាហ៍ពិពាហ៍ ........ ៤២
២.២. ការបែងចែកទ្រព្យសម្បត្តិរបស់សហព័ន្ធ ........ ៤៥
២.២.១. ការបែងចែកតាមការព្រមព្រៀងរបស់សហព័ន្ធ ........ ៤៥

២.២.២ ការបែងចែកតាមសេចក្តីសម្រេចរបស់តុលាការ ........ ៤៦

ក. ការសម្គាល់មុខទ្រព្យសម្បត្តិ ........ ៤៧

ខ. ការចាត់ប្រភេទនៃទ្រព្យសម្បត្តិ ........ ៤៧

គ. ការវាយតម្លៃទ្រព្យសម្បត្តិ ........ ៤៨

ឃ. ការប្រគល់ទ្រព្យសម្បត្តិដោយឡែក ........ ៤៨

ង. ការបែងចែកទ្រព្យសម្បត្តិរួម ........ ៤៨

**សេចក្តីសន្និដ្ឋាន** ........ ៥១

**ឧបសម្ព័ន្ធ** ........

**ឯកសារយោង** ........

# សេចក្តីផ្តើម

តាមប្រពៃណីទំនៀមទម្លាប់របស់ខ្មែរ នៅពេលដែលកូនប្រុសស្រីរបស់ខ្លួនបានដល់វ័យជំទង់ ឪពុកម្តាយតែងតែយកចិត្តទុកដាក់ក្នុងការស្វែងរកគូរស្រករដល់កូនរបស់ខ្លួន ដើម្បីបង្កើតគ្រួសារ និងបន្តវង្សត្រកូលរបស់ខ្លួនពីមួយជំនាន់ទៅមួយជំនាន់ទៀត។ ហេតុដូច្នេះហើយ ទើបនាំឲ្យមាន ចំណងអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីដែលស្ម័គ្រចិត្តរួមរស់ជាប្តីប្រពន្ធ រួមសុខ រួមទុក្ខជាមួយគ្នា និងបង្កើតគ្រួសារដ៏មានសុភមង្គលមួយ។

ចំណងអាពាហ៍ពិពាហ៍ វាមិនគ្រាន់តែបញ្ជាក់ឲ្យបានដឹងថា បុរស និងស្ត្រីបានរួមរស់ជាមួយគ្នា ស្របទៅតាមទំនៀមទម្លាប់ប្រពៃណីតែប៉ុណ្ណោះទេ លើសពីនេះ គឺវាមានអានុភាពនៅផ្លូវច្បាប់ទៀត ផង។ ដូច្នេះអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារឹកមួយដែលបង្កើតឡើងរវាងបុរសម្នាក់ និង ស្ត្រី ម្នាក់ដែលបានស្ម័គ្រចិត្ត និងព្រមព្រៀងរួមរស់ជាប្តីប្រពន្ធជាមួយគ្នា ក្នុងគោលបំណងបង្កើតសិទ្ធិ និងកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកតាមប្រព័ន្ធច្បាប់។ ប្រសិនបើយើងពិនិត្យទៅមើលចំណង អាពាហ៍ពិពាហ៍ គឺវាទាក់ទងទៅនឹងរឿងឯកជន ហេតុអ្វីបានជារាជរដ្ឋាភិបាលជ្រៀតជ្រែកក្នុងរឿង ឯកជនទៅវិញ? អាពាហ៍ពិពាហ៍ វាមិនត្រឹមតែជារឿងឯកជនប៉ុណ្ណោះទេ នៅក្នុងទិដ្ឋភាពខ្លះទៀត វាក៏ជារឿងដែលទាមទារការយកចិត្តទុកដាក់ជាសាធារណៈផងដែរ ដូចនេះហើយ ទើប រាជរដ្ឋាភិបាលបានតាក់តែងច្បាប់មួយចំនួនដែលចែងអំពីអាពាហ៍ពិពាហ៍។ យោងតាម ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានចែងនូវមាត្រាមួយចំនួនដែលទាក់ទង ទៅនឹងអាពាហ៍ពិពាហ៍ផងដែរ ដែលក្នុងនោះរួមមានដូចជា៖ លក្ខខណ្ឌសម្រាប់រៀបអាពាហ៍ពិពាហ៍ សិទ្ធិនិងកាតព្វកិច្ចរបស់ប្តីប្រពន្ធ ការលែងលះ ការលុបចោលឬមោឃភាពនៃអាពាហ៍ពិពាហ៍ លើស ពីនេះទៅទៀតក៏បានចែងអំពីការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដែលយើងនឹងធ្វើការសិក្សា ចំពោះប្រធានបទនេះ។ ប្រធានបទ ការគ្រប់គ្រងទ្រព្យរបស់សហព័ទ្ធ គឺចង់បង្ហាញអំពីសិទ្ធិ និង កាតព្វកិច្ចរបស់ប្តីប្រពន្ធ ក្នុងការថែរក្សា ចាត់ចែងទ្រព្យសម្បត្តិដែលទ្រព្យសម្បត្តិនេះបានកើតមាន មុនអាពាហ៍ពិពាហ៍ ព្រមទាំងអំឡុងពេលអាពាហ៍ពិពាហ៍។ ចំពោះចំណុចនេះផងដែរ មានសំណួរ គតិយុត្តមួយបានចោទឡើងថា៖ " តើបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងអំពី សិទ្ធិ និង កាតព្វកិច្ចក្នុងការថែរក្សា ចាត់ចែងទ្រព្យសម្បត្តិរបស់សហព័ទ្ធត្រូវបានអនុវត្តយ៉ាងដូច ម្តេច?"

ដើម្បីឆ្លើយតបទៅនឹងសំណួរខាងលើ ជាមុនដំបូងយើងគួរយល់ដឹងអំពីប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិជាមុនសិន។ ដោយយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធត្រូវបានបែងចែកចេញជាពីរប្រភេទគឺៈ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា (ជំពូកទី១) និង ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈច្បាប់កំណត់ (ជំពូកទី២)។ ដូច្នេះ យើងនឹងធ្វើការសិក្សាទាក់ទងទៅនឹង ប្រព័ន្ធនីមួយៗនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធឲ្យបានស៊ីជម្រៅទាំងអស់គ្នា។

# ជំពូកទី១

## ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា

ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា គឺប្រព័ន្ធមួយដែលច្បាប់បានចែងទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដោយប្តីប្រពន្ធទាំងសងខាងបានព្រមព្រៀងបង្កើតកិច្ចសន្យាក្នុងការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិក្នុងរង្វង់គ្រួសាររបស់ខ្លួន។ ដើម្បីស្វែងយល់កាន់តែច្បាស់អំពី ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា យើងគួរយល់ដឹងនូវពាក្យគន្លឹះមួយចំនួនជាមុនសិនដូចជាពាក្យ "គ្រប់គ្រង" "ទ្រព្យសម្បត្តិ" "សហព័ទ្ធ" និង "កិច្ចសន្យា" ជាដើម។ ពាក្យថា "គ្រប់គ្រង" តាមន័យនៅក្នុងវចនានុក្រមរបស់សម្តេចជួន ណាត បានពន្យល់ថាពាក្យ គ្រប់គ្រង មានន័យថា បីបាច់ រក្សា ថែទាំដោយទទួលរងបន្ទុករងខុសត្រូវលើខ្លួន។ រីឯពាក្យថា "ទ្រព្យសម្បត្តិ" តាមវចនានុក្រមដដែលបានពន្យល់ថា ទ្រព្យសម្បត្តិ មានន័យថា វត្ថុ ធនធាន សម្បត្តិ។ ខ្មែរយើងប្រើពាក្យនេះ ចំពោះតែវត្ថុមានមាសប្រាក់ជាដើមដែលមានម្ចាស់។ ពាក្យថា "សហព័ទ្ធ" ដោយយោងតាមសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីបានឲ្យនិយមន័យពាក្យសហព័ទ្ធ ថា ប្តី ប្រពន្ធ ឬ ទាំងប្តី ទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ ពាក្យ "កិច្ចសន្យា" ដោយយោងតាមសន្ទានុក្រមដដែលបានឲ្យនិយមន័យថាជា កិរិយា ដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ច។ ដូច្នេះ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា គឺសំដៅទៅលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយសហព័ទ្ធបានបង្ហាញឆន្ទៈព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានចែងអំពី សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធក្នុងការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិសហព័ទ្ធ ។

នៅក្នុងប្រទេសជឿនលឿនមួយចំនួន បានអនុវត្តគោលការណ៍នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាយូរយារណាស់មកហើយ។ ក៏ប៉ុន្តែ ចំពោះព្រះរាជាណាចក្រកម្ពុជាយើងវិញ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺនៅមានលក្ខណៈថ្មីសម្រាប់កម្ពុជាដែលពីមុនមកមិនធ្លាប់មានឡើយ ពីព្រោះគោលការណ៍ការចុះបញ្ជីកិច្ចសន្យានេះ ទើបតែមានចែង និង អនុវត្តនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែកិច្ចសន្យានេះ មិនអាចផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបាន ឡើយ ។[1]

ដោយយោងទៅតាមមាត្រាខាងលើបានបញ្ជាក់ថា ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អនុញ្ញាតឲ្យអនាគតប្តីប្រពន្ធ អាចធ្វើការចុះបញ្ជីកិច្ចសន្យានេះ មុនពេលពួកគេឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍។ ចំណែកឯប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារួចហើយ ក៏អាចធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតាមក្រោយក៏បានដែរ។ លក្ខណៈពិសេសរបស់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺវាអាចបញ្ជាក់ឲ្យបានច្បាស់អំពីសិទ្ធិលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនោះ ថាតើទ្រព្យសម្បត្តិប្រភេទណាខ្លះដែលជាសិទ្ធិរួម? ហើយទ្រព្យសម្បត្តិប្រភេទណាខ្លះដែលជាសិទ្ធិផ្តាច់មុខរបស់ភាគីណាមួយ? លើសពីនេះទៅទៀត ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏បានផ្តល់លក្ខណៈងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិនៅក្រោយពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។ ចំពោះការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះផងដែរ ប្រសិនបើយើងពិនិត្យទៅមើលសង្គមខ្មែរបច្ចុប្បន្ន តើយើងមានសេចក្តីក្លាហានក្នុងការសួរកូនគេ តើអ្នកទ្រព្យសម្បត្តិប៉ុន្មាន នៅពេលដែលយើងចូលទៅស្តីដណ្តឹងកូនស្រីគេដែរឬទេ? ករណីមួយទៀត គឺទោះបីជាក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា តើយើងហ៊ានសួរសហព័ទ្ធយើងថា តើគួរកំណត់ទ្រព្យសម្បត្តិឲ្យបានច្បាស់ថា ទ្រព្យសម្បត្តិមួយណាជាទ្រព្យសម្បត្តិរួម ទ្រព្យសម្បត្តិមួយណាទៀតជាទ្រព្យសម្បត្តិដោយឡែកដែរឬទេ? ដូច្នេះហើយ វានៅតែមានការលំបាកក្នុងការអនុវត្តនីតិវិធីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន។

ទោះបីជាយ៉ាងណាក៏ដោយ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺនៅតែមានលក្ខណៈល្អ និង លក្ខណៈពិសេសសម្រាប់ប្តីប្រពន្ធគួរឲ្យជ្រើសរើស ពីព្រោះវាអាចកំណត់ទ្រព្យសម្បត្តិប្តីប្រពន្ធបានច្បាស់លាស់។ បន្ថែមពីនេះ នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមានលក្ខណៈងាយស្រួលដែលយើងនឹងធ្វើការសិក្សាទាំងអស់គ្នា។ ជាមុនដំបូង យើងគួរយល់ដឹងអំពីបទប្បញ្ញត្តិទូទៅនៃពាក្យសុំចុះបញ្ជី (ផ្នែកទី១)ជាមុនសិន តើសហព័ទ្ធ ឬអនាគតប្តីប្រពន្ធត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីទទួលបានការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ? ព្រមទាំងចុងក្រោយយើងនឹងសិក្សាអំពីការកែប្រែ និង ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ផ្នែកទី២) តើនីតិវិធីនៃ

[1] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩។

ការកែប្រែកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវធ្វើឡើងយ៉ាងដូចម្តេច ហើយតើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានបញ្ចប់តាមរបៀបណាខ្លះ?

## ផ្នែកទី១ បទប្បញ្ញត្តិទូទៅនៃពាក្យសុំចុះបញ្ជី

អនាគតប្តីប្រពន្ធ ឬ សហាព័ទ្ធ ដែលមានគោលបំណងក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមុនពេលរៀបអាពាហ៍ពិពាហ៍ក្តី ឬ ក្រោយរៀបអាពាហ៍ពិពាហ៍ក្តី ត្រូវតែដាក់ពាក្យស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការចុះបញ្ជីកិច្ចសន្យានោះ។ តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាយើង នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងការចុះបញ្ជីត្រូវបានអនុលោមទៅតាមប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមានអនុម័តនាពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣ ហើយបានអនុវត្តកាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ កន្លងមកនេះ។ ក្នុងការប្រកាសនេះផងដែរ បានចែងអំពីទម្រង់បែបបទក្នុងការដាក់ពាក្យសុំចុះបញ្ជី ព្រមទាំងបានបញ្ជាក់អំពីស្ថាប័នដែលមានសមត្ថកិច្ចក្នុងការធ្វើការចុះបញ្ជី ដែលយើងនឹងធ្វើការសិក្សាដូចខាងក្រោម។

### ១.១. ពាក្យសុំចុះបញ្ជី

រាល់ទម្រង់បែបបទពាក្យសុំចុះបញ្ជីទាំងអស់ សហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវបំពេញពាក្យសុំចុះបញ្ជីឲ្យបានច្បាស់លាស់ជៀសវាងក្នុងការច្រានចោល យកទៅកែតម្រូវ ឬបន្ថែមចំនុចណាមួយ។ លើសពីនេះផងដែរ ការដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធ ត្រូវភ្ជាប់ជាមួយនឹងលិខិតបែបបទមួយចំនួនក្នុងការចុះបញ្ជី។ ដូច្នេះ ដើម្បីស្វែងយល់កាន់តែច្បាស់អំពីពាក្យសុំនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ យើងត្រូវយល់ដឹងអំពីលក្ខខណ្ឌសំខាន់ៗរបស់ការដាក់ពាក្យសុំចុះបញ្ជី។ ក្នុងនោះផងដែរ មានលក្ខខណ្ឌពីរដែលសហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវបំពេញតាម គឺ លក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

#### ១.១.១. លក្ខខណ្ឌគ្រឹះ

ចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏ដូចទៅនឹងទម្រង់កិច្ចសន្យាផ្សេងៗទៀតផងដែរ ដែលសហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវបំពេញលក្ខខណ្ឌគ្រឹះបីសំខាន់ គឺ ការព្រមព្រៀង សមត្ថភាព និងកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

### ក. ការព្រមព្រៀង

ការព្រមព្រៀង គឺសំដៅទៅលើការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត។[2] ការព្រមព្រៀងរវាងសហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធ គឺជារឿងសំខាន់ក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលនាំឲ្យមានអានុភាពទៅតាមផ្លូវច្បាប់។ រាល់សហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធ ដែលមានបំណងក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ត្រូវមានការយល់ព្រម ការព្រមព្រៀង ឬ ការបង្ហាញឆន្ទៈស្របគ្នាជាមុនសិន។ ប្រសិនបើក្នុងករណីមានសហាព័ទ្ធតែម្ខាង ឬ អនាគតប្តីប្រពន្ធតែម្ខាង មានឆន្ទៈក្នុងការបង្កើតកិច្ចសន្យានេះ ក៏ប៉ុន្តែមិនមានការយល់ព្រមពីភាគីម្ខាងទៀតទេនោះ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏មិនអាចបង្កើតឡើងបានឡើយ។

ដូច្នេះ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវមានការព្រមព្រៀង ឬ ការយល់ព្រម រវាងសហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធទាំងសងខាង ទើបអាចឈានទៅដល់ការបង្កើតកិច្ចសន្យានេះ។

### ខ. សមត្ថភាព

ជាទូទៅ រាល់កិច្ចសន្យាទាំងអស់សមត្ថភាពរបស់គូភាគី គឺចង់សំដៅទៅលើនីតិជន (ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ) ដែលមានសមត្ថភាពអាចបង្ហាញឆន្ទៈដោយផ្ទាល់ ព្រមទាំងអាចយល់ដឹងអំពីអំពើ និង វិនិច្ឆ័យអំពីអំពើរបស់ខ្លួនបាន។ ចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធសមត្ថភាពរបស់គូភាគី គឺមិនត្រឹមតែសំដៅទៅលើនីតិជននោះទេ ថែមទាំងសំដៅទៅលើអាពាហ៍ពិពាហ៍មួយដែលស្របទៅនឹងច្បាប់ទៀតផង។ សហាព័ទ្ធ មានបំណងចង់បង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានត្រូវមានអាពាហ៍ពិពាហ៍មួយដែលស្របច្បាប់ដែលសំដៅទៅលើ លិខិតអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ឬ សំបុត្រអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ឬ ដែលអាចហៅបានយ៉ាងទៀតគឺ អេតាស៊ីវិល (Elate Civil) ដែលប្រជាជនកម្ពុជាភាគច្រើនបានស្គាល់នឹងដឹងអំពីវាជាអ្វី។

ចំពោះចំណុចខាងលើនេះផងដែរ យើងអាចបញ្ជាក់បានថា អាពាហ៍ពិពាហ៍មួយដែលមានអានុភាពទៅតាមផ្លូវច្បាប់ គឺមិនសំដៅទៅលើការធ្វើពិធីមង្គលការទៅតាមប្រពៃណីទំនៀមទម្លាប់ ឬ បានអញ្ជើញភ្ញៀវជាច្រើនបានដឹងបានឃើញអំពីពិធីមង្គលការរបស់ខ្លួនឡើយ។ វាគឺចង់សំដៅទៅ

[2] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣១០។

លើ តើអាពាហ៍ពិពាហ៍នោះបានគោរពទៅតាមលក្ខខណ្ឌនៃច្បាប់ដែលឬទេ? ហើយប្តីប្រពន្ធបានចុះសំបុត្រ ឬ លិខិតអាពាហ៍ពិពាហ៍ឬនៅ?

អាពាហ៍ពិពាហ៍មួយដែលស្របតាមគតិយុត្តត្រូវគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

- ភេទរបស់ភាគីៈ ដោយយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីភេទរបស់ភាគីដែលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន លុះត្រូវតែមានភេទផ្ទុយគ្នាគឺរវាងបុរស និង ស្ត្រីតែប៉ុណ្ណោះ។[3] រីឯចំពោះបុគ្គលស្រឡាញ់ភេទដូចគ្នាច្បាប់មិនបានអនុញ្ញាតឲ្យចុះបញ្ជីសំបុត្រអាពាហ៍ពិពាហ៍ឡើយ។

- គោលការណ៍ស្ម័គ្រចិត្តៈ បុរស និង ស្ត្រីដែលចង់រៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវមានគោលការណ៍ស្ម័គ្រចិត្តទាំងសងខាង ដោយគ្មានបុគ្គលណាមួយអាចបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយខ្លួនបានឡើយ។ ចំពោះ ឪពុកម្តាយ អាណាព្យាបាល ឬ តតិយជនក៏មិនអាចបង្ខិតបង្ខំបុគ្គលណាមួយឲ្យទៅរៀបអាពាហ៍ពិពាហ៍ ដោយបុគ្គលនោះមិនបានបង្ហាញឆន្ទៈស្ម័គ្រចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ឡើយ។ គោលការណ៍ស្ម័គ្រចិត្តនេះផងដែរ គឺមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៥ ថា " អាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងតាមលក្ខខណ្ឌក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ។"

- លក្ខខណ្ឌអាយុៈ បុគ្គលដែលអាចរៀបអាពាហ៍ពិពាហ៍បាន គឺត្រូវតែជានីតិជន(ជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើយទៅ)។ ប៉ុន្តែក្នុងករណី ភាគីម្ខាងជានីតិជន និង ភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ឆ្នាំ ក៏អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដោយត្រូវមានការយល់ព្រមពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់អនីតិជននោះ។ [4] ចំពោះករណីដែលឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលរបស់អនីតិជនតែម្ខាងបានធ្វើការយល់ព្រម អនីតិជននោះក៏អាចរៀបអាពាហ៍ពិពាហ៍បានដែរ។ រីឯករណីបើគ្មានការយល់ព្រមរបស់ឪពុកម្តាយ ឬ អ្នកអាណាព្យាបាលរបស់អនីតិជនដោយគ្មានមូលហេតុសមរម្យ

[3] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨។

[4] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨។

អនីតិជននោះ អាចទាមទារទៅតុលាការឲ្យសម្រេចសេចក្តីជំនួសការយល់ព្រមរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលបាន។[5]

- គោលការណ៍ឯកពន្ធភាព៖ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៤៥ បានកំណត់គោលការណ៍ប្តីមួយប្រពន្ធមួយ។ ដូច្នេះ បុរស ឬ ស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍ចាស់នៅមានសុពលភាព ហើយចង់រៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតមិនអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍បានឡើយ។[6]

- អំឡុងពេលហាមរៀបអាពាហ៍ពិពាហ៍ថ្មី៖ ប្រសិនបើអាពាហ៍ពិពាហ៍មុនត្រូវបានលុបចោល ឬ រំលាយនារីត្រូវរងចាំរយៈពេល ១២០ថ្ងៃ (គិតពីចំណងអាពាហ៍ពិពាហ៍ចាស់បានរំលត់) ទើបអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ក៏ប៉ុន្តែក្នុងករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ហើយបានសម្រាលកូន ឬ ករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិតនារីមិនបាច់ធ្វើការរង់ចាំឡើយ។[7]

- អាពាហ៍ពិពាហ៍រវាងញាតិលោហិត៖ អាពាហ៍ពិពាហ៍ដែលធ្វើឡើងរវាងញាតិខ្សែផ្ទាល់ (ទាំង៦ថ្នាក់) ឬ សាខាញាតិក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ គឺមិនអាចធ្វើបានឡើយ។ ចំពោះសាខាញាតិថ្នាក់ទី ៤ (បងប្អូនជីដូនមួយ) អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន។[8]

លក្ខខណ្ឌទាំងអស់ខាងលើ គឺជាចំណុចសំខាន់ដែលភាគីទាំងសងខាងត្រូវគោរពតាម។ ប្រសិនបើបានបំពេញលក្ខខណ្ឌទាំងអស់គ្រប់គ្រាន់ហើយ ប្តីប្រពន្ធត្រូវនាំគ្នាទៅដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ រួចជូនដំណឹងជាសាធារណៈ បន្ទាប់មកចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ព្រមទាំងធ្វើការចុះបញ្ជីនៅមុខមន្ត្រីអត្រានុកូលដ្ឋានជាការស្រេច[9] ដែលជាហេតុនាំឲ្យ អាពាហ៍ពិពាហ៍នេះមានអានុភាពគតិយុត្ត និងចាត់ទុកថាស្របទៅនឹងច្បាប់។

[5] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៣។

[6] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៩។

[7] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥០។

[8] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥១។

[9] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៥។

### គ. កម្មវត្ថុ

នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធមានសិទ្ធិសេរីភាពក្នុងការកំណត់សិទ្ធិ ឬ កាតព្វកិច្ចទៅលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ទាំងទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម ដោយមានការយល់ព្រមពីសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធទាំងសងខាង។ តើអ្វីទៅជាទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម? ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ន្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ព្រមទាំងទ្រព្យសម្បត្តិជាតម្លៃតបនៃទ្រព្យសម្បត្តិដោយឡែកផងដែរ។ [10] ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ហើយលើកលែងទ្រព្យសម្បត្តិដោយឡែកចេញ។[11]

សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធអាចកំណត់នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដូចជា៖

- ទ្រព្យសម្បត្តិដោយឡែក ដាក់ឲ្យទៅជាទ្រព្យសម្បត្តិរួម។ ឧទាហរណ៍៖ ការប្រាក់នៃប្រាក់សន្សំក្នុងធនាគារនៅពេលមុនរៀបអាពាហ៍ពិពាហ៍ ដែលជាទ្រព្យសម្បត្តិដោយឡែកទៅជាទ្រព្យសម្បត្តិរួម។[12]
- ទ្រព្យសម្បត្តិរួម ដាក់ឲ្យទៅជាទ្រព្យសម្បត្តិដោយឡែក។ ឧទាហរណ៍៖ ចំណូល ឬ ប្រាក់ខែរបស់ប្តីប្រពន្ធម្នាក់ៗ ដាក់ទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួន (ប៉ុន្តែ ផ្អែកតាមមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដោយមិនអនុញ្ញាតឲ្យចែងផ្ទុយពីសិទ្ធិទាមទារអាហារកាតព្វកិច្ច ដូចនេះនៅពេលដែលសហព័ន្ធណាម្ខាងបានបាត់បង់ចំណូលនោះសហព័ន្ធម្ខាងទៀតត្រូវទ្រទ្រង់ជាចាំបាច់)។
- កំណត់អំពីទំនាក់ទំនងកាតព្វកិច្ច និង សិទ្ធិលើបំណុលជាពិសេស ការចាត់ចែងកាតព្វកិច្ចដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និងបន្ទុកនៃកាតព្វកិច្ចជាក់លាក់ដែលអាចនឹងកើតឡើងក្រោយអាពាហ៍ពិពាហ៍ជាអាទិ៍។

---

[10] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២។

[11] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

[12] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការប្រចាំក្រសួងយុត្តិធម៌ ជំនាញការផ្នែកច្បាប់ អ៊ីសូអ៊ី មីហា, *កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ* (២០១៤), ៣។

- កំណត់អំពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ (ដូចជាសិទ្ធិគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យដោយឡែករបស់ប្តីឲ្យទៅប្រពន្ធជាដើម។

ទោះបីជាសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធមានសិទ្ធិសេរីភាពក្នុងការកំណត់ក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធយ៉ាងណាក៏ដោយ ក៏ច្បាប់បានកំណត់នូវវិធានមួយចំនួន ដើម្បីគ្រប់គ្រងទៅលើកិច្ចសន្យានោះផងដែរ។ យោងទៅតាមមាត្រា ៩៦៩នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់ថា សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធមិនអាចបំពានសិទ្ធិទាមទារអាហារកាតព្វកិច្ច[13] និង ភាគបម្រុង[14]នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានឡើយ។ លើសពីនេះទៅ សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធ មិនអាចកំណត់ខ្លឹមសារផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ។ ឧទាហរណ៍៖ ករណីដែលមានការព្រមព្រៀងថា ទ្រព្យសម្បត្តិដែលទទួលបានក្រោយរៀបអាពាហ៍ពិពាហ៍ទាំងអស់ត្រូវក្លាយជារបស់សហព័ទ្ធម្ខាង។ ករណីនេះ បើមើលពីគំនិតនៃសមភាពបុរសស្ត្រី គឺមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលវាមិនត្រូវបានអនុញ្ញាតទេ។

### ១.១.២. លក្ខខណ្ឌទម្រង់

ជាទូទៅទម្រង់នៃកិច្ចសន្យាត្រូវបានបែងចែកជាពីរទម្រង់ គឺកិច្ចសន្យាផ្ទាល់មាត់ និង កិច្ចសន្យាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាផ្ទាល់មាត់ គឺជាប្រភេទនៃកិច្ចសន្យាដែលមិនបានសរសេរជាលាយលក្ខណ៍អក្សរ ហើយយើងតែងតែប្រើវាទាក់ទិនទៅនឹងជីវភាពប្រចាំថ្ងៃ (ដូចជា ការលក់ទិញអាហារ ការលក់ទិញសម្ភារៈតូចតាចមួយចំនួន) ប៉ុន្តែបើយើងពិនិត្យទៅមើលអំពីអានុភាពគតិយុត្តរបស់វាវិញ គឺមិនសូវមានប្រសិទ្ធភាពប៉ុន្មានទេ ពីព្រោះពេលខ្លះនៅពេលដែលភាគីទាំងសងខាងព្រមព្រៀងគ្នា មិនមានអ្នកដឹងលឺ និង គ្មានភស្តុតាងជាក់លាក់ដើម្បីយកមកបញ្ជាក់នៅតុលាការ។ រីឯកិច្ចសន្យាលាយលក្ខណ៍អក្សរវិញ គឺជាកិច្ចសន្យាមួយប្រភេទដែលភាគីទាំងសងខាងនៅពេលបង្កើតកិច្ចសន្យានេះបានសរសេរជាលាយលក្ខណ៍អក្សរ ដែលបានបញ្ជាក់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងសងខាងយ៉ាងច្បាស់លាស់។ កិច្ចសន្យាលាយលក្ខណ៍អក្សរ គឺមានអានុភាពគតិយុត្តខ្លាំង

[13] អាហារកាតព្វកិច្ច គឺជា កិច្ច ដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការដែលតម្រូវអោយបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅបុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងញាតិនឹងគ្នា។

[14] ភាគបម្រុង គឺជាភាគនៃទ្រព្យសម្បត្តិរបស់មតកជន ដែលបច្ឆាញាតិផ្ទាល់ ឬ ឪពុក ម្តាយ ឬជីដូន ជីតា និងសហព័ន្ធរបស់មតកជននោះ អាចទាមទារបាន តាមការកំណត់របស់ច្បាប់។

ដែលភាគីទាំងសងខាងត្រូវតែគោរពតាម ពីព្រោះវាមានភស្តុតាងច្បាស់លាស់ដើម្បីយកមកបញ្ជាក់នៅតុលាការ។

លក្ខណៈពិសេសរបស់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺត្រូវតែធ្វើជាទម្រង់លាយលក្ខណ៍អក្សរ ហើយខ្លឹមសារនៃកិច្ចសន្យានេះត្រូវតែធ្វើការចុះបញ្ជី។ ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យាផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេនោះ កិច្ចសន្យានេះក៏មិនអាចយកមកតតាំងជាមួយនឹងតតិយជនបានឡើយ។[15] ដូច្នេះ ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនបានចុះបញ្ជីទេ នោះមិនអាចអះអាងចំពោះតតិយជនបានឡើយ។

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្រៅពីត្រូវសរសេរជាលាយលក្ខណ៍អក្សរហើយ ត្រូវបំពេញទម្រង់បែបបទ និង ភ្ជាប់មកជាមួយនឹងលិខិតមួយចំនួនដូចខាងក្រោម។

### ក. ទម្រង់បែបបទពាក្យសុំចុះបញ្ជី

ទម្រង់នៃពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជីបន្ថែមពីនេះទៀត ត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និង អាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍។[16]

ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ រាល់ច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ។ ជាគោលការណ៍ ពាក្យសុំចុះបញ្ជីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវធ្វើឡើងរួមគ្នា។ លើកលែងតែករណី ការផ្លាស់ប្តូរ ឬ ការកែតម្រូវ

[15] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧០។

[16] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ១៦,១៩។

ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ដែលសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធតែម្ខាងអាចមកធ្វើការកែប្រែបាន។ នៅពេលដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏អាចធ្វើឡើងដោយអ្នកតំណាងបានផងដែរ។ អ្នកតំណាងត្រូវយកពាក្យសុំចុះបញ្ជីនេះ ដាក់នៅចំពោះមន្ត្រីចុះបញ្ជីជំនួសសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធ។[17]

### ខ. ឯកសារភ្ជាប់

សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវភ្ជាប់មកនូវឯកសារមួយចំនួន នៅពេលដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមានដូចជា៖

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ហាដីធ្លី
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន
- ចំពោះអ្នកតំណាងដែលដាក់ពាក្យសុំចុះបញ្ជីជំនួសសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងមកជាមួយ។[18]

ឯកសារដែលភ្ជាប់ជាមួយនឹងពាក្យសុំ អ្នកដាក់ពាក្យសុំអាចទាមទារប្រគល់វិញនៅពេលដាក់ពាក្យសុំ។ ដើម្បីទាមទារឲ្យប្រគល់ឯកសារភ្ជាប់មកវិញ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនេះនូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសគ្នាពីច្បាប់ដើម។ ចំពោះលិខិតប្រគល់សិទ្ធិតំណាង គឺមិនត្រូវបានប្រគល់មកវិញបានឡើយ។[19]

[17] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ១៥។

[18] ដូច១៧, ប្រការ១៩។

[19] ដូច១៧, ប្រការ១៨។

## ១.២. នីតិវិធីនៃការចុះបញ្ជី

សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធដែលមានបំណងក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្រៅពីបានបំពេញសំណុំបែបបទ និង លក្ខខណ្ឌទាំងអស់ខាងលើរួចរាល់ហើយ សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវតែយកកិច្ចសន្យានេះ ទៅចុះបញ្ជីនៅស្ថាប័នមានសមត្ថកិច្ចដែលទទួលបន្ទុកក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ទាក់ទងទៅនឹង នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមានចែងនៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលបានអនុម័តកាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣។ ដោយក្នុងប្រកាសនេះផងដែរ បានបញ្ជាក់អំពីស្ថាប័នមានសមត្ថកិច្ចក្នុងការទទួលបន្ទុកការចុះបញ្ជី ការទទួលការពិនិត្យពាក្យសុំចុះបញ្ជី របៀបចុះបញ្ជី ព្រមទាំងការចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីផងដែរ។ ចំពោះចំណុចទាំងអស់ខាងលើនេះ យើងនឹងធ្វើការសិក្សាដូចតទៅ។

### ១.២.១. ស្ថាប័នមានសមត្ថកិច្ច

ក្រសួងមានសមត្ថកិច្ចក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមានចែងនៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ២៦ ដោយបានចែងថា៖ "កិច្ចការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។"

លើសពីនេះ នៅក្នុងក្រសួងយុត្តិធម៌ ការិយាល័យដែលមានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ដោយមានមន្ត្រីដែលទទួលបន្ទុកក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយមន្ត្រីទទួលបន្ទុកចំពោះការចុះបញ្ជីនេះ គឺត្រូវស្ថិតនៅក្នុងការដឹកនាំរបស់នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី។ ព្រមទាំងរាល់ឯកសារទាំងអស់ត្រូវបានគ្រប់គ្រង និងតម្កល់ទុកនៅក្នុងនាយកដ្ឋាននេះផងដែរ។[20]

នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ត្រូវបង្កើតក្រូណូ[21] ចំនួន ៦ ដែលទាក់ទងទៅនឹងការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធដោយក្នុងនោះរួមមាន៖

[20] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ប្រក/១៣, ០៩ សីហា ២០១៣, ប្រការ៥។

[21] ក្រូណូ គឺជាសម្ភារៈការិយាល័យមួយយ៉ាងដែលសម្រាប់ទុកឯកសារ ។

– ក្រូណូទទួលពាក្យសុំ៖ គឺជាក្រូណូសម្រាប់ចុះព័ត៌មាន ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និង ចុះលេខទទួលពាក្យសុំនៅលើពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីស្តីពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ពាក្យសុំលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ដោយសន្លឹកក្រដាសទទួលពាក្យទាំងអស់ដែលដាក់ក្នុងក្រូណូបានបែងចែកជាតារាងតាមខ្ទង់នីមួយៗដូចខាងក្រោម៖

- លេខរៀងទទួលពាក្យ
- កាលបរិច្ឆេទនៃការទទួលពាក្យ
- ប្រភេទនៃការចុះបញ្ជីកិច្ចសន្យាសម្បត្តិប្តីប្រពន្ធ
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- ជាប្តីប្រពន្ធ
- បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) [22]

– ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ៖ គឺជាក្រូណូសម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិ ចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះបញ្ជីអំពីការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ចំពោះសន្លឹកចុះបញ្ជីដែលក្នុងក្រូណូ ក៏ត្រូវបានបែងចែកជាតារាងតាមខ្ទង់ដូចខាងក្រោម៖

- លេខចុះបញ្ជី និង លេខទទួលពាក្យសុំ
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និង អាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណង និង មូលហេតុនៃការចុះបញ្ជី
- ខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការលុបចោលការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ[23]

[22] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ប្រក/១៣, ០៩ សីហា ២០១៣, ប្រការ៦។

[23] ដូច២២, ប្រការ៧។

- ក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ៖ គឺជាក្រូណូសម្រាប់ដាក់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ដែលមន្ត្រីចុះបញ្ជីបានទទួលពីអ្នកដាក់ពាក្យសុំ។[24]

- ក្រូណូលើកចោល៖ គឺជាក្រូណូសម្រាប់ដាក់លិខិតលើកចោលពាក្យសុំចុះបញ្ជីរបស់មន្ត្រីចុះបញ្ជី។[25]

- ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ៖ គឺជាក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ព្រមទាំងដាក់សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឯកសារដែលភ្ជាប់មកជាមួយ។[26]

- ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី៖ គឺជាក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យធ្វើការបញ្ជាក់ ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។[27]

ចំពោះក្រូណូទទួលពាក្យសុំ និង ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឯកសារទាំងអស់ត្រូវបានរក្សាទុកជារៀងរហូត។ រីឯក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ ក្រូណូលើកចោល ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ និងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ឯកសារទាំងអស់ដែលនៅក្នុងក្រូណូទាំង៤ នេះ ត្រូវបានរក្សាទុកត្រឹមរយៈពេល ១០ឆ្នាំ គិតចាប់ពីថ្ងៃទទួល ឬចេញលិខិត ។

### ១.២.២. ការទទួលពាក្យសុំចុះបញ្ជី

នៅពេលដែលទទួលនូវសំណុំលិខិតស្នើសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មន្ត្រីចុះបញ្ជីត្រូវធ្វើការពិនិត្យទៅលើលក្ខខណ្ឌរួម ខ្លឹមសារ និងទម្រង់បែបបទមួយចំនួនដែលបានភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនោះ។ ប្រសិនបើសំណុំលិខិតស្នើសុំដែលបានដាក់មកនោះ បានបំពេញ

[24] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ប្រក/១៣, ០៩ សីហា ២០១៣, ប្រការ៨។

[25] ដូច២៤, ប្រការ៩។

[26] ដូច២៤, ប្រការ១០។

[27] ដូច២៤, ប្រការ១១។

គ្រប់គ្រាន់នូវរាល់លក្ខខណ្ឌដែលតម្រូវហើយ មន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះនូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និង ឈ្មោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ព្រមទាំងហត្ថលេខាបំព្រួញ និង ឈ្មោះមន្ត្រីចុះបញ្ជីនោះ។

ប៉ុន្តែ ប្រសិនបើសំណុំលិខិតស្នើសុំមិនទាន់បានបំពេញពេញលេញទៅតាមលក្ខខណ្ឌច្បាប់បានកំណត់នោះទេ មន្ត្រីទទួលបន្ទុកត្រូវចេញលិខិតបង្គាប់ឲ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ និង ជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ព្រមទាំងត្រូវផ្តល់មូលហេតុកន្លែងខ្វះខាតទៅអ្នកដាក់ពាក្យសុំបានដឹងផងដែរ។ ក្នុងករណីអ្នកដាក់ពាក្យសុំមិនបានធ្វើការកែតម្រូវតាមការណែនាំរបស់មន្ត្រីចុះបញ្ជីទេ មន្ត្រីចុះបញ្ជីត្រូវចេញលិខិតលើកចោលពាក្យសុំចុះបញ្ជីនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំ។ នៅពេលពាក្យសុំចុះបញ្ជីត្រូវបានលើកចោល រាល់សំណុំឯកសារ និង ឯកសារភ្ជាប់ទាំងអស់នឹងត្រូវប្រគល់មកវិញ បើមានការស្នើសុំរបស់អ្នកដាក់ពាក្យសុំ។ ចំពោះការលើកចោលពាក្យសុំរបស់មន្ត្រីចុះបញ្ជី អ្នកដាក់ពាក្យសុំមានសិទ្ធិដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្រោយពេលពិនិត្យឡើងវិញ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងសម្រេច ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំនោះវិញ។[28]

ចំពោះអនាគតប្តីប្រពន្ធនៅពេលចុះបញ្ជីមិនទាន់បានរៀបអាពាហ៍ពិពាហ៍ ក្រោយពីបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សហព័ទ្ធនោះត្រូវដាក់ពាក្យសុំចុះបញ្ជីបន្ថែមអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចធ្វើការដកពាក្យសុំនោះមកវិញនៅមុនពេលការចុះបញ្ជីត្រូវបានបញ្ចប់ ហើយអ្នកពាក្យសុំដកការចុះបញ្ជីនេះត្រូវធ្វើជាលិខិតលាយលក្ខណ៍អក្សរ។

អានុភាពនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺនៅពេលដែលមានការចុះហត្ថលេខា និង ប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

[28] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ប្រក/១៣, ០៩ សីហា ២០១៣, ប្រការ៣៤។

### ១.២.៣. របៀបចុះបញ្ជី

របៀបនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ រាល់ពាក្យសុំទាំងអស់ត្រូវសរសេរចូលទៅតាមប្រភេទនៃក្រូណូដែលគ្រប់គ្រងដោយនាយកដ្ឋានរដ្ឋប្បវេណី។ ដោយក្រូណូទាំងអស់នោះ គឺមានបកស្រាយដូចខាងលើ ដែលយើងបានធ្វើការសិក្សារួចមកហើយ។ ដូច្នេះ របៀបនៃការចុះបញ្ជីគឺត្រូវបានអនុវត្តទៅប្រភេទនៃពាក្យសុំ ព្រមទាំងប្រភេទនៃក្រូណូនីមួយៗ។

នៅពេលដែលមន្ត្រីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកក្រដាសពាក្យសុំនូវព័ត៌មានទាំងឡាយ ដែលអ្នកដាក់ពាក្យសុំបានបំពេញចូលទៅក្នុងក្រូណូទទួលពាក្យសុំជាមុនសិន។ បន្ទាប់មកទៀត មន្ត្រីចុះបញ្ជីត្រូវពិនិត្យមើលពាក្យសុំ និង ឯកសារភ្ជាប់មកជាមួយស្របទៅនឹងច្បាប់កំណត់ដែរឬទេ? ប្រសិន អ្នកដាក់ពាក្យសុំបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ហើយ មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកចុះបញ្ជីនូវចំណុចទាំងអស់ដែលតម្រូវសរសេរចូលទៅក្នុងក្រូណូចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ សន្លឹកចុះបញ្ជីនោះ ត្រូវចុះលេខចុះបញ្ជីដោយផ្អែកលើលេខរៀងទទួលពាក្យសុំ ហើយមន្ត្រីចុះមន្ត្រីត្រូវចុះហត្ថលេខាបំព្រួញ ដើម្បីបញ្ជាក់បានថាបានពិនិត្យរួច បន្ទាប់មកទៀតត្រូវយកសន្លឹកចុះបញ្ជីបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច។

ចំពោះក្រូណូចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬការកែប្រែកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្រូណូចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏ត្រូវបានអនុវត្តដូចគ្នាទៅនឹងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធផងដែរ។ មុនដំបូង មន្ត្រីចុះបញ្ជីត្រូវពិនិត្យពាក្យសុំរួចត្រូវសរសេរព័ត៌មានដែលទាក់ទងទាំងអស់ទៅក្នុងសន្លឹកទៅតាមប្រភេទក្រូណូនីមួយៗ។ បន្ទាប់មកទៀតយកសន្លឹកទាំងនោះ បញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង ធ្វើសេចក្តីសម្រេច ព្រមទាំងចុះហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ១.២.៤. ការចេញលិខិតបញ្ជាក់

ក្រោយពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានធ្វើការចុះបញ្ជីរួចរាល់ សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធអាចសុំលិខិតបញ្ជាក់អំពីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ប្រសិនមានតម្រូវការរបស់សហព័ទ្ធ ឬ អនាគតប្តីប្រពន្ធ។ រាល់ការសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី គឺមិនមែនធ្វើ

ឡើងដោយផ្ទាល់មាត់បានឡើយ ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។ ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ត្រូវតែសរសេរចូលនូវចំណុចដូចខាងក្រោម៖

- គោលបំណងនៃពាក្យសុំ៖ ការសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬស្នាមម្រាមដៃ។

ក្រោយពីអ្នកដាក់ពាក្យសុំបំពេញចំណុចទាំងអស់នៃពាក្យសុំឲ្យចេញលិខិតបញ្ជាក់រួច អ្នកដាក់ពាក្យសុំត្រូវយកពាក្យសុំនោះទៅដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌។ មន្ត្រីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីដែលនៅក្នុងក្រូណូចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធ ទៅឲ្យអ្នកដាក់ពាក្យសុំដោយបញ្ជាក់នៅលើឯកសារបញ្ជាក់អំពីការថតចម្លងត្រឹមត្រូវ ចុះកាលបរិច្ឆេទ ព្រមទាំងមានហត្ថលេខាបំព្រួញរបស់មន្ត្រីចុះបញ្ជី និង ការចុះហត្ថលេខា ប្រថាប់ត្រារបស់រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ផងដែរ។ ចំពោះការចេញលិខិតបញ្ជាក់នេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចឲ្យរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការរដ្ឋប្បវេណីចុះហត្ថលេខាជំនួស។ ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចេញលិខិតបញ្ជាក់ឲ្យទៅអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវយ៉ាងយូរបំផុតមិនឲ្យលើសពីរយៈពេល ៣ ថ្ងៃ។[29]

បន្ថែមពីនេះ រាល់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវរក្សាទុកនូវពាក្យសុំនោះនៅក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជីទៅតាមលំដាប់លេខ និងកាលបរិច្ឆេទនៃពាក្យសុំ។

[29] ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ៣៩។

# ផ្នែកទី២ ការកែប្រែ និង ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅពេលចំណាងអាពាហ៍ពិពាហ៍បានចាប់ផ្តើម ព្រមទាំងនីតិវិធីនៃការចុះបញ្ជីក៏បានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ត្រឹមត្រូវទៅតាមច្បាប់រួចរាល់ហើយនោះ អានុភាពរបស់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏បានបង្កើតសិទ្ធិ និងកាតព្វកិច្ចប្តីប្រពន្ធអោយគោរពធ្វើតាមអ្វីៗដែលបានចែងក្នុងកិច្ចសន្យានោះ ចាប់ពីថ្ងៃបានចុះបញ្ជីកិច្ចសន្យា។ ក្នុងករណីមានសហព័ទ្ធណាម្ខាងបានប្រព្រឹត្តផ្ទុយទៅនឹងចំណុចណាមួយនៃកិច្ចសន្យា សហព័ទ្ធម្ខាងទៀតមានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីអនុវត្តតាមនីតិវិធីទៅតាមច្បាប់ក្នុងការរកដំណោះស្រាយទៅដល់សហព័ទ្ធទាំងសងខាង។ រីឯការកែប្រែ និងផ្លាស់ប្តូរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមិនមានលក្ខណៈខុសគ្នាជាមួយនឹងកិច្ចសន្យាមួយចំនួនឡើយ។ ក្រោយពេលដែលភាគីទាំងសងខាងបានអនុវត្ត ហើយបានពិនិត្យឃើញថាមានចំណុចខ្វះណាមួយ ឬ មានបំណងចង់បំពេញបន្ថែមទៅលើចំណុចណាមួយ ភាគីទាំងសងខាងគឺមានសិទ្ធិក្នុងការកែតម្រូវ ឬផ្លាស់ប្តូរបាន ក៏ប៉ុន្តែចំណុចដែលសំខាន់នោះគឺត្រូវតែមានការព្រមព្រៀងរវាងភាគីទាំងសងខាងជាមុនសិន។ ប្រសិនមានភាគីណាម្ខាងមិនបានបង្ហាញឆន្ទៈការយល់ព្រមនោះទេ កិច្ចសន្យានេះក៏មិនអាចធ្វើការកែតម្រូវ ឬផ្លាស់ប្តូរបានឡើយ។ បន្ថែមពីនេះ ចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លក្ខណៈពិសេសរបស់វាមួយទៀត គឺរាល់ការកែតម្រូវ ឬផ្លាស់ប្តូរទាំងឡាយត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងត្រូវធ្វើចុះបញ្ជីចំណុចដែលបានកែតម្រូវ ឬផ្លាស់ប្តូរនោះ ប្រសិនបើមិនដូច្នេះទេ ចំណុចដែលបានកែតម្រូវ ឬ ផ្លាស់ប្តូរគឺមិនអាចតតាំងជាមួយនឹងតតិយជនបានឡើយ។ ចំពោះមូលហេតុនៃការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមិនខុសគ្នានឹងប្រព័ន្ធគ្រប់គ្រងទៅតាមច្បាប់ឡើយ ដែលនាំឲ្យកិច្ចសន្យានេះនឹងត្រូវបានលុបចោល។

ដើម្បីស្វែងយល់កាន់តែច្បាស់អំពី ការកែតម្រូវ និងការបញ្ចប់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ យើងនឹងធ្វើការសិក្សាទាំងអស់គ្នាដូចខាងក្រោម។

## ២.១. ការផ្លាស់ប្តូរ ឬ កែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ដូចដែលបានបញ្ជាក់ខាងលើ រាល់ការផ្លាស់ប្តូរ ឬ កែតម្រូវចំណុចណាមួយនៃកិច្ចសន្យាសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ រួចយកកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះទៅធ្វើការចុះបញ្ជីថ្មី។ ក្នុងករណីសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធបានព្រមព្រៀងគ្នាធ្វើឡើងតាមផ្ទាល់មាត់ចំណុចដែលបានធ្វើការផ្លាស់ប្តូរ ឬកែតម្រូវនោះគឺមិនមានអានុភាពគតិយុត្តឡើយ។ ជាហេតុនាំឲ្យ

ប្តី ឬ ប្រពន្ធមិនអាចតតាំងជាមួយតតិយជននូវចំណុចការផ្លាស់ប្តូរ ឬកែតម្រូវនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមិនបានធ្វើការចុះបញ្ជីនោះ។ ដូច្នេះ ប្តីប្រពន្ធ ឬ អនាគតប្តីប្រពន្ធបើមានបំណងក្នុងការផ្លាស់ប្តូរ ឬកែតម្រូវចំណុចណាមួយនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវសរសេរពាក្យសុំផ្លាស់ប្តូរ ឬកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទៅស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីជាថ្មីទៅលើកិច្ចសន្យានោះ។

ចំពោះពាក្យសុំផ្លាស់ប្តូរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ពាក្យសុំកែតម្រូវនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមានលក្ខណៈខុសគ្នា។ ក៏ប៉ុន្តែបើយើងពិនិត្យទៅមើលពាក្យ "ការផ្លាស់ប្តូរ" និង "ការកែតម្រូវ" គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាដែលយើងពិបាកក្នុងការបែងចែកថា មួយណាគឺការផ្លាស់ប្តូរ មួយណាទៀតគឺជាការកែតម្រូវ។ ក្នុងករណីដែលយើងដាក់ពាក្យខុស វានឹងពិបាកក្នុងការដាក់ពាក្យសុំមួយដងទៀត។ ដូច្នេះ ដើម្បីយល់កាន់តែច្បាស់ យើងនឹងសិក្សាទាំងអស់គ្នាចំពោះចំណុចទាំងនេះ តើពាក្យសុំផ្លាស់ប្តូរ និង ពាក្យសុំកែតម្រូវខុសគ្នាយ៉ាងដូចម្តេច?

### ២.១.១. ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ក្រោយពីបានចុះបញ្ជីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលើកដំបូងរួចរាល់ហើយ គឺវាមិនមានន័យថា សហព័ទ្ធ ឬអនាគតប្តីប្រពន្ធ មិនអាចធ្វើការផ្លាស់ប្តូរអត្ថន័យនៃកិច្ចសន្យានោះបានទេ។ រាល់ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិ គឺត្រូវបានបើកចំហ និង ផ្តល់សិទ្ធិសេរីភាពទៅឲ្យសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធធ្វើការផ្លាស់ប្តូរចំណុចណាមួយក៏បានដែរ ឲ្យតែមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងក្នុងការផ្លាស់ប្តូរកិច្ចសន្យានេះ ព្រមទាំងការផ្លាស់ប្តូរនោះមិនអាចផ្ទុយទៅនឹងបទប្បញ្ញត្តិដែលច្បាប់បានចែង។

ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺសំដៅទៅលើសហព័ទ្ធ ឬអនាគតប្តីប្រពន្ធទាំងសងខាងបានព្រមព្រៀងគ្នាក្នុងការផ្លាស់ប្តូរចំណុចណាមួយ ដែលបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិរួចមកហើយ។ ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ភាគច្រើនសំដៅទៅលើការផ្លាស់ប្តូរសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ប្រភេទនៃទ្រព្យសម្បត្តិ។

ឧទាហរណ៍៖ លោក "ក" និង អ្នកស្រី "ខ" បានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមានប្រការមួយបានចែងថា៖ "រាល់តម្លៃតបដែលទទួលបានមកពីទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ត្រូវចាត់ទុកទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិ

ដោយឡែក។" ប៉ុន្តែក្រោយពីបានចុះបញ្ជីរួចរាល់ហើយនោះ លោក "ក" និង អ្នកស្រី "ខ" មានបំណងចង់ផ្លាស់ប្តូរវាទៅជាទ្រព្យសម្បត្តិរួមដោយគិតថា ធ្វើបែបនេះអាចជួយចែករំលែកបន្ទុកគ្រួសារចំពោះគ្នាទៅវិញទៅមក។ ដូចនេះ លោក "ក" និង អ្នកស្រី "ខ" បានព្រមព្រៀងគ្នាធ្វើពាក្យសុំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយបានផ្លាស់ប្តូរប្រការខាងលើទៅជា៖ "រាល់តម្លៃតបដែលទទួលបានមកពីទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ត្រូវចាត់ទុកទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិរួម។"

រាល់ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ព្រមទាំងធ្វើការចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ បើមិនដូច្នេះទេរាល់ការផ្លាស់ប្តូរទាំងអស់មិនមានអានុភាពគតិយុត្តឡើយ។ ចំពោះពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សហព័ទ្ធ ឬអនាគតប្តីប្រពន្ធត្រូវសរសេរកិច្ចសន្យាទ្រព្យសម្បត្តិថ្មីមួយទៀតដោយបញ្ជាក់អំពីមូលហេតុនៃការផ្លាស់ប្តូរ ព្រមទាំងចំណុចដែលបានធ្វើការផ្លាស់ប្តូរទៅលើពាក្យសុំចុះនោះ។ ឯកសារដែលត្រូវភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីមានដូចជា៖

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- សាលក្រម ឬដីកាសម្រេចផ្លាស់ប្តូរ
- លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន (ប្រសិនចំណុចដែលផ្លាស់ប្តូរទាក់ទងនឹងការផ្លាស់ប្តូរអាសយដ្ឋាន)
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការផ្លាស់ប្តូរ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន[30]។

### ២.១.២. ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទម្រង់បែបបទនៃការចុះបញ្ជីគឺមិនមានលក្ខណៈខុសគ្នាប៉ុន្មានទេ។ គ្រាន់តែការកែតម្រូវកិច្ចសន្យា

[30] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ២០។

ទ្រព្យសម្បត្តិប្តីប្រពន្ធ គឺសំដៅលើនៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានចុះបញ្ជីរួចហើយ សហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជីចំណុចណាមួយសហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវដាក់ពាក្យសុំចុះបញ្ជីកែតម្រូវ។[31]

ការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិដែលមានកំហុស គឺសំដៅទៅលើការកែតម្រូវចំណុចដែលបានសរសេរខុស ឬ បំពេញខុស។ ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលបានធ្វើការចុះបញ្ជីរួច ប្តីប្រពន្ធបានពិនិត្យឃើញថា ឈ្មោះ របស់លោក "ក" បានសរសេរខុសដោយបានសរសេរជា លោក "គ" ។ ដូចនេះ ប្តីប្រពន្ធអាចដាក់ពាក្យសុំចុះបញ្ជីអំពីកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិនោះ។ ការកែតម្រូវដែលទាក់ទងទៅនឹងអត្តសញ្ញាណរបស់បុគ្គលណាមួយ គឺអាចធ្វើឡើងដោយបុគ្គល(ប្តី ឬ ប្រពន្ធ) តែម្ខាងបាន។

ចំពោះការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិដែលមានការខកខានមិនបានចុះបញ្ជី គឺសំដៅទៅលើការកែតម្រូវ ឬបំពេញបន្ថែមនៃទ្រព្យសម្បត្តិណាមួយមិនបានចែងនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនបានចែងទាក់ទងទៅនឹងដីរបស់លោក "ក" (ប្តី) ដែលស្ថិតនៅខេត្តរតនៈគីរី។ ដូចនេះ សហាព័ទ្ធ ឬ អនាគតប្តីប្រពន្ធត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្នុងការបំពេញបន្ថែមនូវចំណុចខ្វះខាតដែលមិនបានចែងនោះ។

ការដាក់ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ការពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺដូចគ្នាដោយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងត្រូវបញ្ជាក់អំពីចំណុចដែលត្រូវកែតម្រូវ និង មូលហេតុនៃការកែតម្រូវផងដែរ។ ឯកសារដែលត្រូវភ្ជាប់មកជាមួយពាក្យសុំគឺមានដូចជា៖

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍
- លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន(ប្រសិនចំណុចកែតម្រូវទាក់ទងនឹងអាសយដ្ឋាន)

[31] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ២១។

- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការផ្លាស់ប្តូរ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន[32]។

## ២.២. ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺសំដៅទៅលើចំណងអាពាហ៍ពិពាហ៍មួយបានបញ្ចប់ ដែលឈានទៅដល់ការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងធ្វើការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ។ ការបែងចែកទ្រព្យសម្បត្តិនេះ ពេលខ្លះអាចជួបនឹងផលលំបាកមួយចំនួនផងដែរនៅពេលដែលសហព័ទ្ធមិនបានព្រមព្រៀងគ្នាទៅលើការបែកចែក និង សិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិនោះ។ សហព័ទ្ធតែងតែចង់ទាមទារចំណែករបស់ខ្លួនឲ្យបានច្រើនជាងភាគីម្ខាងទៀត ដែលវាជាបញ្ហាមួយដែលតុលាការពិបាកក្នុងការចេញសម្រេចសេចក្តី។ ក៏ប៉ុន្តែ បញ្ហានេះប្រហែលមានភាពងាយស្រួលនៅពេលដែលសហព័ទ្ធ បានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយគ្នា។ ការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធដោយកិច្ចសន្យា ធ្វើឲ្យមានភាពងាយស្រួលជាងតាមរយៈប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់។ ដោយសារតែភាគីបានព្រមព្រៀងគ្នាក្នុងការបង្កើតកិច្ចសន្យារួចទុកជាមុន សហព័ទ្ធត្រូវបែងចែកទ្រព្យសម្បត្តិផ្អែកទៅតាមកិច្ចសន្យាដែលបានចុះជាមួយគ្នានោះ។

ការបញ្ចប់ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈកិច្ចសន្យា និង ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈច្បាប់ គឺមិនមានលក្ខណៈខុសគ្នាឡើយ។ វានឹងបាត់បង់អានុភាពនៅពេលដែលចំណងអាពាហ៍ពិពាហ៍មួយត្រូវបានបញ្ចប់ ក៏ជាហេតុនាំកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានលុបចោលផងដែរ។ យើងនឹងធ្វើការសិក្សា តើមានមូលហេតុអ្វីខ្លះដែលជាហេតុនាំឲ្យកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានលុបចោល?

[32] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ២១។

### ២.២.១. ការរំលាយចំណងអាពាហ៍ពិពាហ៍ ឬ កំដាច់ពាក្យ

ចំណងអាពាហ៍ពិពាហ៍ទាំងអស់មិនមែនសុទ្ធតែរាល់សហព័ទ្ធអាចរួមរស់ជាមួយគ្នារហូតដល់ចាស់ស្លាប់ឡើយ។ សហព័ទ្ធមួយចំនួនរួមរស់ជាមួយគ្នាបានរយៈពេល១ឆ្នាំ ឯសហព័ទ្ធមួយចំនួនទៀតរួមរស់ជាមួយគ្នាបានត្រឹមតែ៣ខែក៏អាចឈានទៅការរំលាយចំណងអាពាហ៍ពិពាហ៍បានដែរ។

មូលហេតុនៃការរំលាយចំណងអាពាហ៍ពិពាហ៍ គឺមានទិដ្ឋភាពបួនយ៉ាងដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាយើងដូចជា៖

- ការលែងលះ ៖ ចំណងអាពាហ៍ពិពាហ៍ជាច្រើនត្រូវបានរំលាយដោយសារសហព័ទ្ធបង្ហាញឆន្ទៈមិនចុះសម្រុងរវាងគ្នា ការលែងលះត្រូវធ្វើឡើងដោយឆ្លងកាត់តុលាការ គឺត្រូវមានសេចក្តីសម្រេចដែលជាសាលក្រម ឬសាលដីការបស់តុលាការ សម្រេចឲ្យសហព័ទ្ធលែងលះ។ ចំពោះការលែងលះ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧បានចែងទាក់ទិនទៅនឹងមូលហេតុដែលសហព័ទ្ធអាចដាក់ពាក្យបណ្តឹងលែងលះគ្នាបានដោយកំណត់ថា៖
    - បើបានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ
    - បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ
    - បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាងមួយឆ្នាំ
    - បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍
    - ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។[33]
    - ការលែងលះគ្នាសហព័ទ្ធក៏អាចធ្វើឡើងបានផងដែរក្នុងករណីមានការព្រមព្រៀងគ្នារវាងសហព័ទ្ធ។[34]
- មោឃភាពអាពាហ៍ពិពាហ៍៖ ក្នុងករណីអាពាហ៍ពិពាហ៍បានធ្វើឡើងដោយគ្មានឆន្ទៈយល់ព្រមរៀបអាពាហ៍ពិពាហ៍ ការភ័ន្តច្រឡំលើបុគ្គល ការបង្ខំ និងមូលហេតុផ្សេងទៀត

[33] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨។

[34] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៩។

អាពាហ៍ពិពាហ៍នេះនឹងត្រូវបានចាត់ទុកជាមោឃៈ។ បន្ថែមពីនេះទៀត អាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយមិនបានដាក់ពាក្យសុំរៀបការ ឬ កង្វះខាតលើការជូនដំណឹងសាធារណៈអាពាហ៍ពិពាហ៍នោះក៏ត្រូវបានចាត់ទុកជាមោឃៈផងដែរ។[35]

- ការលុបចោលអាពាហ៍ពិពាហ៍៖ អាពាហ៍ពិពាហ៍ត្រូវបានលុបចោលក្នុងករណីដែលអាពាហ៍ពិពាហ៍នោះមិនគោរពនូវលក្ខខណ្ឌនៃអាយុរៀបការ ការបំពានលើលក្ខខណ្ឌដែលបានហាមឃាត់ចំពោះអាពាហ៍ពិពាហ៍រវាងញាតិ ទ្វេពន្ធភាព អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី ការឆបោក ឬ ការគម្រាម។ អាពាហ៍ពិពាហ៍ណាមួយ ដែលបានធ្វើឡើងក្នុងលក្ខខណ្ឌណាមួយនៃទិដ្ឋភាពខាងលើ អាពាហ៍ពិពាហ៍នោះនឹងត្រូវបានធ្វើការលុបចោល។ អ្នកដែលមានសិទ្ធិក្នុងការដាក់ពាក្យការលុបចោលអាពាហ៍ពិពាហ៍មានដូចជា ភាគីនីមួយ (ប្តីឬប្រពន្ធ) ញាតិសន្តានរបស់ជននោះ ឬ សហព័ទ្ធមុន ឬតំណាងអយ្យការអាចទាមទារទៅតុលាការ ដើម្បីលុបចោលអាពាហ៍ពិពាហ៍ណាមួយ។
- មរណភាពរបស់សហព័ទ្ធម្ខាង៖ មរណភាពរបស់ភាគីណាម្នាក់នៃសហព័ទ្ធ ក៏ជាហេតុនាំឲ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយដែរ។ មរណភាពជាកត្តានាំមកនូវគោលការណ៍ជម្រះបញ្ជីពីរគឺ ការបែងចែកទ្រព្យសម្បត្តិរួមនៃគ្រួសារ និង សន្តតិកម្ម។ ដោយសហព័ទ្ធបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមុនពេលសហព័ទ្ធម្ខាងទៀតបានទទួលមរណៈ ការបែងចែកទ្រព្យសម្បត្តិ គឺត្រូវបានអនុវត្តទៅតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងកិច្ចសន្យានោះ។

ទាំងអស់នេះហើយ សុទ្ធតែជាមូលហេតុដែលសំខាន់ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ដែលបង្កើតអានុភាពនៃការបែងចែកទ្រព្យសម្បត្តិ ព្រមទាំងឈានទៅដល់ការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធផងដែរ។ រាល់ការរំលាយអាពាហ៍ពិពាហ៍ ភាគីត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ អំពីការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅកាន់មន្ត្រីចុះបញ្ជីដោយភ្ជាប់ជាមួយនឹងដីកាសម្រេច សាលក្រម ឬសាលដីការំលាយអាពាហ៍ពិពាហ៍ដែលចូលជាស្ថាពរ។ បន្ថែមពីនេះទៅទៀត ក្នុងករណីសហព័ទ្ធម្ខាងបានទទួលមរណភាព សហព័ទ្ធម្ខាងទៀតត្រូវដាក់ពាក្យសុំលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយភ្ជាប់នូវលិខិតមរណភាពមកជាមួយ។

[35] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៨។

ចំណែកកំជាប់ពាក្យវិញ គឺជាសេចក្តីសន្យាដែលបានធ្វើឡើងរវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត និងដោយធ្វើពិធីកំជាប់ពាក្យ។[36] ជាភាសាទូទៅ យើងទាំងអស់គ្នាតែងតែហៅថា ការភ្ជាប់ពាក្យ។

ដោយសារតែប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យា បានអនុញ្ញាតឲ្យបុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន។ នៅពេលកំជាប់ពាក្យនោះបានរំលាយ ភាគីត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានចុះបញ្ជីកន្លងមក។ ចំពោះពាក្យសុំលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវភ្ជាប់មកជាមួយនឹងកិច្ចព្រមព្រៀង ឬការជូនដំណឹងពីការរំលាយកំជាប់ពាក្យ។ រីឯអនាគតប្តីប្រពន្ធណាម្ខាងបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរួចហើយ បានទទួលមរណភាពមុនពេលរៀបអាពាហ៍ពិពាហ៍ ភាគីម្ខាងទៀតត្រូវដាក់ពាក្យសុំលុបចោលកិច្ចសន្យានោះដោយភ្ជាប់មកជាមួយនឹងលិខិតមរណភាពរបស់ភាគីដែលទទួលមរណៈ។

### ២.២.២. មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមានលក្ខណៈដូចគ្នាទៅនឹងកិច្ចសន្យាទូទៅ ចំពោះផ្នែកការមោឃភាព ការលុបចោល និង ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ទោះបីជាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទទួលបានការត្រួតពិនិត្យ និងការចុះបញ្ជីក៏ដោយ មិនមានន័យថាកិច្ចសន្យានេះគឺមិនកំហុសឡើយ។ ដូច្នេះហើយ ជាហេតុនាំឲ្យកិច្ចសន្យានេះទទួលរងនូវការធ្វើមោឃភាព ការលុបចោល និងការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

មូលហេតុដែលនាំឲ្យ កិច្ចសន្យាមួយធ្វើការមោឃភាពនោះ គឺដោយសារអត្ថន័យនៃកិច្ចសន្យាបានផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ កិច្ចសន្យានេះអាចធ្វើការមោឃភាពបាន។ លើសពីនេះទៀត កិច្ចសន្យាណាដែលផ្ទុយទៅនឹងទម្រង់ដែលត្រូវបានទាមទារដោយក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ឬ ច្បាប់ដែលចូលជាធរមានកិច្ចសន្យានោះក៏អាចធ្វើការមោឃៈផងដែរ។[37]

[36] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៩។

[37] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៥៧។

ចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លក្ខខណ្ឌដែលអាចធ្វើការមោឃភាពបាន គឺមានទិដ្ឋភាពជាច្រើន ដូចជា៖ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានធ្វើការបែងចែកការគ្រប់គ្រងទ្រព្យសម្បត្តិដោយបង្ខំឬមិនសមភាព ឬ អត្ថន័យនៃកិច្ចសន្យាបានផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ប្រពៃណី។ល។ ជាពិសេស ដោយយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនអនុញ្ញាតឲ្យធ្វើផ្ទុយពីបទប្បញ្ញត្តិសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ។ ក្នុងករណី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធណាមួយ មិនបានអនុវត្តតាមបទបញ្ញត្តិនេះទេ កិច្ចសន្យានេះនឹងអាចធ្វើការមោឃភាពបាន។

ចំណែកឯមូលហេតុដែលភាគី(ប្តី ឬ ប្រពន្ធ) នៃកិច្ចសន្យាអាចធ្វើការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាននោះ គឺនៅពេលដែលកិច្ចសន្យាមានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ក្នុងច្បាប់។ វិការៈក្នុងការបង្ហាញឆន្ទៈមានដូចជា៖ ការភ័ន្តច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគម្រាមកំហែង និង អំពើកេងយកចំណេញហួសហេតុជាដើម។

ឧទាហរណ៍៖ លោក "ក" និង អ្នកស្រី "ខ" បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាអស់ជាច្រើនឆ្នាំ មានថ្ងៃមួយលោក "ក" បានឲ្យអ្នកស្រី "ខ" ធ្វើកិច្ចសន្យាទ្រព្យសម្បត្តិ ដោយក្នុងកិច្ចសន្យានេះបានកំណត់រាល់ទ្រព្យសម្បត្តិដោយឡែករបស់អ្នកស្រី "ខ" ចាត់ទុកជាទ្រព្យសម្បត្តិរួម បើមិនដូច្នេះទេ លោក "ក" នឹងដាក់ពាក្យបណ្តឹងសុំលែងលះ ។ ដោយអ្នកស្រី "ខ" គិតគូរដល់អនាគតរបស់កូន ក៏បានចុះហត្ថលេខាទៅលើកិច្ចសន្យានោះ។ ដូច្នេះហើយ អ្នកស្រី "ខ" អាចសុំលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ដោយផ្អែកថានៅពេលបង្កើតកិច្ចសន្យាគឺមានការគម្រាមកំហែងពីប្តី។

រីឯការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺអាចកើតឡើងនៅពេលសហព័ទ្ធណាម្ខាង ឬ អនាគតប្តីប្រពន្ធណាម្ខាង មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលមានចែងក្នុងកិច្ចសន្យា។ ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បានកំណត់អំពីការគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នារវាងប្តីនិងប្រពន្ធ។ ក៏ប៉ុន្តែ ប្រពន្ធបានគ្រប់គ្រងទ្រព្យសម្បត្តិរួមទាំងអស់ដោយមិនអនុញ្ញាតឲ្យប្តីគ្រប់គ្រងឡើយ។ ដូច្នេះ ប្តីអាចដាក់ពាក្យបណ្តឹងសុំរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន។

មូលហេតុទាំងអស់នេះហើយ ដែលជាហេតុនាំឲ្យកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានធ្វើការមោឃភាព លុបចោល ឬរំលាយ។ កិច្ចសន្យានេះ ក៏ត្រូវបានបាត់បង់អានុភាពរបស់វាផងដែរ។ ទោះបីជា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានមោឃភាព លុបចោល ឬ រំលាយ ភាគីណាម្ខាង គឺត្រូវដាក់ពាក្យសុំលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលាយលក្ខណ៍អក្សរ រួម

ជានឹង សាលក្រម ឬសាលដីកាស្ដីពីការមោឃភាព លុបចោល ឬ រំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលចូលជាធរមានទៅកាន់មន្ត្រីចុះបញ្ជី ដើម្បីធ្វើការលុបចោលការចុះបញ្ជីនោះ។

### ២.២.៣. សេចក្តីសម្រេចរបស់តុលាការ

នៅពេលសហព័ទ្ធបានជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈកិច្ចសន្យា វាបានផ្តល់ការងាយស្រួល ទៅដល់តុលាការធ្វើការសម្រេចសេចក្តីអំពីការបែងចែកទ្រព្យសម្បត្តិ។ ជាទូទៅ ក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតែងតែកំណត់អំពីទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែកបានច្បាស់លាស់ ជាហេតុនាំឲ្យការប្រព្រឹត្តទៅនៃការបែងចែកទ្រព្យសម្បត្តិកាន់តែងាយស្រួល។ លើសពីនេះទៅទៀត កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមួយចំនួន ក៏បានចែងបទបញ្ញត្តិទាក់ទងទៅនឹងការបែងចែកទ្រព្យសម្បត្តិផងដែរ។ ដូច្នេះតុលាការចេញសម្រេចសេចក្តីទៅតាមអ្វីដែលមានចែងនៅក្នុងកិច្ចសន្យានេះ គឺជាការស្រេចដោយមិនមានការលំបាកក្នុងការបែងចែកទ្រព្យសម្បត្តិឡើយ។

ទោះបីជាយ៉ាងណាក៏ដោយ មិនមែនន័យថា រាល់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទាំងអស់សុទ្ធតែបានចែងច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយឡើយ តែងតែមានចំណុចខ្វះខាតជាមិនខានឡើយ។ ដូចនេះ ក្នុងករណីមានទំនាស់គ្នាដែលគេមិនអាចធ្វើការបែងចែកបាន ឬខ្លឹមសារនៃកិច្ចសន្យាចែងមិនបានច្បាស់លាស់ ភាគីនៅតែអាចប្តឹងទៅតុលាការដើម្បីអោយធ្វើអន្តរាគមន៍បែងចែកជំនួសភាគីបាន តែចៅក្រមនឹងរិះរកដំណោះស្រាយក្នុងការបែងចែក ដោយខិតខំស្វែងរកឲ្យឃើញនូវឆន្ទៈពិតរបស់ភាគី ដែលបានបង្ហាញនៅក្នុងពេលចុះកិច្ចសន្យា ឬ ស្វែករកឲ្យឃើញឆន្ទៈពិតរបស់ភាគីដែលមានចែងក្នុងខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅពេលភាគីបានព្រមព្រៀងចុះកិច្ចសន្យាជាមួយគ្នា។[38]

ដូចនេះ តុលាការនៅតែមានសិទ្ធិក្នុងការបកស្រាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្នុងករណីកិច្ចសន្យានេះមានការចែងមិនបានច្បាស់លាស់។

[38] ឥន យឿន, *នីតិគ្រួសារ និង អាពាហ៍ពិពាហ៍* (២០១៣), ២៖៣-៤។

# ជំពូកទី២

## ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់

ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់ គឺសំដៅទៅលើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធទៅតាមអ្វីដែលច្បាប់បានកំណត់ ព្រមទាំងយកមកអនុវត្តក្នុងសង្គមគ្រួសារនីមួយៗ។

ប្រទេសកម្ពុជាយើងក៏ជាប្រទេសមួយ ដែលបានទទួលយកនូវប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់ គឺត្រូវបានយកមកអនុវត្តនៅក្នុងប្រទេសយើងផងដែរ។ ប្រព័ន្ធនេះក៏ត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាយើងអស់ជាច្រើនឆ្នាំមកហើយ។ គោលការណ៍នៃប្រព័ន្ធនេះត្រូវបានចែងយ៉ាងលម្អិតនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងត្រូវបានអនុវត្តដោយស្វ័យប្រវត្តិ ប្រសិនបើសហព័ទ្ធមិនបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមុនពេល ឬ អំឡុងពេលមានចំណងអាពាហ៍ពិពាហ៍នោះទេ។

គោលការណ៍ដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា គឺបានបញ្ជាក់យ៉ាងច្បាស់ពីការកំណត់នូវសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងការចាត់ចែងលើទ្រព្យសម្បត្តិរបស់សហព័ទ្ធជាដើម។ ដោយហេតុថា ប្រសិនបើក្រមរដ្ឋប្បវេណីមិនបានកំណត់នូវគោលការណ៍ទាំងអស់នេះទេ សហព័ទ្ធនីមួយៗប្រាកដជាមានការពិបាកក្នុងការសម្គាល់ថា តើទ្រព្យសម្បត្តិមួយណាជាទ្រព្យសម្បត្តិរួម ហើយទ្រព្យសម្បត្តិមួយណាជាទ្រព្យសម្បត្តិដោយឡែក ហើយវាក៏អាចនឹងមានពិបាកក្នុងការកំណត់អំពីសមត្ថកិច្ចក្នុងការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិផងដែរ។ ដោយហេតុនេះហើយទើបអង្គការនីតិប្បញ្ញត្តិបានធ្វើការបង្កើតនូវគោលការណ៍ទាំងនេះឡើង ដើម្បីគ្រប់គ្រង និងទប់ស្កាត់នូវសកម្មភាពវិវាទដែលអាចនឹងកើតមានឡើង ហើយក៏អាចជាបញ្ហាប្រឈមសម្រាប់សហព័ទ្ធទាំងអស់។ ប្រាកដណាស់ថា ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ គឺតែងតែជាបញ្ហាមួយ ដែលតែងតែកើតមានឡើងនៅក្នុងសង្គមគ្រួសារនីមួយៗនាពេលបច្ចុប្បន្នមិនថាគ្រួសារក្រីក្រ ឬ គ្រួសារអ្នកមាន។ ដូច្នេះហើយទើប រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងរិះរកគ្រប់មធ្យោបាយ ក្នុងការរកដោះស្រាយមួយដ៏ល្អសម្រាប់បញ្ហានេះ។ ដូច្នេះហើយទើប អង្គការមានសមត្ថកិច្ចបានបង្កើតនូវប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់នេះឡើង ដើម្បីធ្វើការកំណត់ពីសមត្ថកិច្ចក្នុងការគ្រប់គ្រង ចាត់ចែងរបស់សហព័ទ្ធទាំងសងខាងទៅលើទ្រព្យសម្បត្តិដែលខ្លួនកំពុងកាន់កាប់។

ដូចនេះដើម្បីយល់ដឹងពីបញ្ហានេះឲ្យកាន់តែច្បាស់ យើងគប្បីស្គាល់ពីប្រភេទទ្រព្យសម្បត្តិ (ផ្នែកទី១) ជាមុនសិនថា តើទ្រព្យសម្បត្តិដែលសហព័ទ្ធកំពុងតែមាននេះ គេចាត់ទុកថាជាប្រភេទនៃទ្រព្យសម្បត្តិអ្វី? ព្រមទាំងមូលហេតុអ្វីខ្លះដែលនាំឲ្យមានការបញ្ចប់នូវប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់នេះ? (ផ្នែកទី២)។

## ផ្នែកទី១ ប្រភេទនៃទ្រព្យសម្បត្តិ

ជាទូទៅប្រទេសនីមួយៗ បានធ្វើការកំណត់ប្រភេទទ្រព្យសម្បត្តិរបស់សហព័ទ្ធខុសៗគ្នាពីប្រទេសមួយទៅ ប្រទេសមួយទៀត។ ការកំណត់ប្រភេទទ្រព្យសម្បត្តិរបស់សហព័ទ្ធនេះ គឺដើម្បីធ្វើការកំណត់នូវសមត្ថកិច្ចក្នុងការប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិនោះ។ ចំពោះប្រទេសកម្ពុជាយើង ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានធ្វើការកំណត់សមត្ថកិច្ចក្នុងការប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងនេះលើ ទ្រព្យសម្បត្តិបានយ៉ាងច្បាស់លាស់។ ដោយក្រមរដ្ឋប្បវេណីនេះ បានបែងចែកប្រភេទទ្រព្យសម្បត្តិជា២ប្រភេទ គឺទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម។ តើអ្វីទៅដែលហៅថាទ្រព្យសម្បត្តិដោយឡែក? ឬទ្រព្យសម្បត្តិរួម? ដើម្បីស្វែងយល់កាន់តែច្បាស់អំពីទ្រព្យសម្បត្តិទាំងពីរនេះ យើងនឹងធ្វើការសិក្សាទាក់ទងទៅនឹងប្រភេទទ្រព្យសម្បត្តិនីមួយៗ ក៏ដូចជាសមត្ថកិច្ចក្នុងការប្រើប្រាស់ គ្រប់គ្រង ចាត់ចែងលើទ្រព្យសម្បត្តិទាំងពីរ នេះឲ្យបានស៊ីជម្រៅដូចខាងក្រោមនេះ។

### ១.១. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺសំដៅទៅលើទ្រព្យសម្បត្តិដែលសហពទ្ធ័មានមុនពេលរៀបអាពាហ៍ពិពាហ៍។ [39] យើងអាចនិយាយបានយ៉ាងងាយថា រាល់ទ្រព្យសម្បត្តិដែលកើតមុនអាពាហ៍ពិពាហ៍ គឺគេចាត់ទុកថាជាទ្រព្យសម្បត្តិដោយឡែកទាំងអស់។

ឧទាហរណ៍៖ បុរស "ក" (ប្ដី)បានបានសន្សំលុយ ពីការធ្វើការងារ និង ការធ្វើអាជីវកម្ម ហើយក៏បានសម្រេចចិត្តក្នុងការទិញឡានមួយមុនពេលខ្លួនធ្វើការរៀបអាពាហ៍ពិពាហ៍ ជាមួយនារី "ខ" (ប្រពន្ធ)។

[39] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២។

លើសពីនេះទៅក៏ត្រូវចាត់ទុកថាជាទ្រព្យដោយឡែកផងដែរ ប្រសិនបើសហព័ទ្ធណាម្ខាង ទទួលបានទ្រព្យសម្បត្តិនោះតាមរយៈដូចជា ប្រទានកម្ម សន្តតិកម្ម អច្ច័យទានជាដើម។ ទោះបីជាទ្រព្យសម្បត្តិដែលបានតាមរយៈដូចខាងលើនេះនៅអំឡុងអាពាហ៍ពិពាហ៍ក៏ដោយ ក៏ទ្រព្យសម្បត្តិនេះត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិដោយឡែកផងដែរ។ ឧទាហរណ៍៖ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ ប្តីបានទទួលនូវផ្ទះមួយល្វែងតាមរយៈប្រទានកម្មពីជីតារបស់ខ្លួន។

ម្យ៉ាងវិញទៀត ក្នុងករណីដែលសហព័ទ្ធណាម្ខាងបានធ្វើការចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនតាមរយៈការជួល ឬ ការប្រវាស់ជាដើម ដែលសកម្មភាពទាំងនេះអាចបង្កើតបាននូវផលប្រយោជន៍នាពេលបច្ចុប្បន្ន ឬ អនាគត ដូចនេះផលប្រយោជន៍ដែលទទួលបានពីទ្រព្យសម្បត្តិដោយឡែកនោះ ក៏ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិដោយឡែកផងដែរ។

ឧទាហរណ៍៖ នារី"ខ"(ប្រពន្ធ) មានផ្ទះជួលមួយកន្លែងដែលមានទីតាំងនៅទីក្រុងភ្នំពេញដែលផ្ទះនេះខ្លួនទទួលបានតាមរយៈសន្តតិកម្មពីឪពុករបស់ខ្លួន ដូចនេះកម្រៃដែលបានមកពីការជួលផ្ទះនោះក៏ត្រូវចាត់ជាទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធផងដែរ។

### **១.១.១. លក្ខណៈបុគ្គលនៃទ្រព្យសម្បត្តិដោយឡែក**

លក្ខណៈបុគ្គលនៃទ្រព្យសម្បត្តិដោយឡែកនេះ គឺសំដៅលើទ្រព្យសម្បត្តិដែលសហព័ទ្ធណាម្ខាងមានមុនពេលអាពាហ៍ពិពាហ៍ដែលទ្រព្យសម្បត្តិនោះអាចជាអចលនទ្រព្យ និងចលនទ្រព្យ។ យោងតាមក្រមរដ្ឋប្បវេណី មាត្រា ១២០ បានកំណត់នូវនិយមន័យនៃទ្រព្យសម្បត្តិទាំងពីរនេះថា អចលនទ្រព្យគឺសំដៅទៅលើ ដីធ្លី វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិជាអាទិ៍។ វាមានន័យថា ត្រូវរាប់បញ្ចូលថាជាអចលនទ្រព្យបាន លុះត្រាតែទ្រព្យសម្បត្តិនោះគឺនៅនឹងមួយកន្លែងមិនអាចធ្វើការផ្លាស់ប្តូរទីកន្លែងបានតាមចិត្តរបស់កម្មសិទ្ធិករបាន។ ចំណែកឯចលនទ្រព្យវិញ គឺក្រមរដ្ឋប្បវេណីបានផ្តល់នូវភាពងាយស្រួលក្នុងការកំណត់ពីទ្រព្យសម្បត្តិនេះ ដែលចលនទ្រព្យគឺសំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយដែលក្រៅពីអចលនទ្រព្យ។ ចលនទ្រព្យនេះគឺសំដៅទៅទ្រព្យដែលអាចផ្លាស់ប្តូរទីកន្លែងទៅតាមចិត្តរបស់កម្មសិទ្ធិករបាន។ ឧទាហរណ៍៖ ដូចជា ឡាន ម៉ូតូ កង់ជាដើម...។ ចំពោះអចលនទ្រព្យ និងចលនទ្រព្យដែលមានមុនអាពាហ៍ពិពាហ៍នេះ សហព័ទ្ធណាម្ខាងគឺត្រូវទទួលសិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ដោយច្បាប់។

### ១.១.២. ប្រភពនៃទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែកនេះអាចកើតពីទិដ្ឋភាពផ្សេងៗ ដែលយើងតែងតែជួបប្រទះនៅក្នុងសង្គមនីមួយៗ ដែលទិដ្ឋភាពនោះមានដូចជាប្រទានកម្ម អច្ច័យទាន និង សន្តតិកម្មជាដើម...។

– ប្រទានកម្មៈ

គឺជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឲ្យទៅភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិ ដោយមិនគិតពីតម្លៃតបស្នង ហើយភាគីម្ខាងទៀតយល់ព្រមទទួលយក។ ឧទាហរណ៍ៈ នារី "ខ" (ប្រពន្ធ) ទទួលបាននូវឡានទំនើបមួយគ្រឿងពីម្តាយរបស់គាត់ក្នុងថ្ងៃខួបកំណើតរបស់ខ្លួន។

– អច្ច័យទានៈ

គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។ ឧទាហរណ៍ៈ នារី "ខ" (ប្រពន្ធ) បានទទួលបាននូវដីមួយកន្លែងពីមីងរបស់ខ្លួនតាម រយៈការធ្វើបណ្តាំនៅមុនពេលដែលគាត់ស្លាប់។

– សន្តតិកម្មៈ

គឺជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬ ច្រើននាក់។ សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ដែលសន្តតិកម្មដោយផ្អែកតាមបញ្ញត្តិច្បាប់ ហៅថាសន្តតិកម្មតាមច្បាប់ និង សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថាសន្តតិកម្មមានបណ្តាំ។[40]

ដូចនេះទិដ្ឋភាពខាងលើនេះ ទ្រព្យសម្បត្តិដោយឡែកអាចត្រូវបានផ្ទេរពីបុគ្គលមួយទៅបុគ្គលមួយទៀតបាន តាមរបៀបផ្សេងៗគ្នាដែលនេះជាប្រភពនៃការកកើតនូវទ្រព្យសម្បត្តិដោយឡែក។ ការទទួលបានទ្រព្យសម្បត្តិពីការផ្ទេរសិទ្ធិពីកម្មសិទ្ធិករនេះ បង្កើតបាននូវសិទ្ធិដូចជា សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និង សិទ្ធិចាត់ចែងដោយស្វ័យប្រវត្តិទៅលើទ្រព្យសម្បត្តិនោះ។ ដោយសិទ្ធិទាំងនេះនឹងត្រូវបានបកស្រាយយ៉ាងលម្អិតនៅចំណុចខាងក្រោមនេះ។

[40] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤៥។

### ១.១.៣. ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដោយឡែក

សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក គឺសំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករ (សហព័ទ្ធណាម្ខាង) មានសិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ គ្រប់គ្រង និងអាស្រ័យផលទៅលើទ្រព្យសម្បត្តិដោយឡែកនោះ។ កម្មសិទ្ធិករអាចប្រើប្រាស់នូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនទៅតាមសេចក្តីត្រូវការរបស់ខ្លួនបាន ក៏ប៉ុន្តែការប្រើប្រាស់នេះត្រូវស្ថិតនៅក្រោមការកំណត់របស់ច្បាប់។ មានន័យថាការប្រើប្រាស់ និង ការគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន គឺមិនត្រូវធ្វើឲ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់របស់សង្គម ឬ បង្កឲ្យមានព្យសនកម្មដល់អ្នកដទៃនោះទេ។ ក្នុងករណីដែលការប្រើប្រាស់ទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនធ្វើឲ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ឬ បានបង្កឲ្យមានព្យសនកម្មដល់អ្នកដទៃ ម្ចាស់កម្មសិទ្ធិ (សហព័ទ្ធណាម្ខាង) គឺត្រូវធ្វើការទទួលខុសត្រូវលើសកម្មភាពនេះដោយផ្ទាល់ខ្លួន ពោលគឺគ្មាននរណាម្នាក់ចូលរួមសហការក្នុងការទទួលខុសត្រូវជាមួយខ្លួនឡើយ ប្រសិនបើនេះជាកំហុស ឬក៏ជាការធ្វេសប្រហែសដែលកើតចេញពីការប្រើប្រាស់ និងការគ្រប់គ្រងរបស់ខ្លួន។ លើសពីនេះទៅទៀត កម្មសិទ្ធិករក៏អាចទទួលបានផលដែលបានពីការចាត់ចែងទ្រព្យសម្បត្តិនោះផងដែរ ដោយគ្មាននរណាម្នាក់មានសិទ្ធិចូលរួមក្នុងការទទួលយកចំណែកនេះបានទេ។

សិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិដោយឡែកនេះ គឺសំដៅទៅលើសិទ្ធិដែលម្ចាស់កម្មសិទ្ធិ (សហព័ទ្ធណាម្ខាង) អាចធ្វើការប្រគល់ ឬ ផ្ទេរសិទ្ធិជាកម្មសិទ្ធិករនេះទៅនរណាម្នាក់ក៏បាន។ កម្មសិទ្ធិករមិនចាំបាច់ មានការយល់ព្រមពីសំណាក់តតិយជនណាម្នាក់ឡើយក្នុងការធ្វើការចាត់ចែងលើទ្រព្យសម្បត្តិដោយឡែកនេះ។ ឧទាហរណ៍៖ សុខ (ប្តី) បានទទួលកាដូឡានមួយគ្រឿងនៅថ្ងៃខួបកំណើតរបស់គាត់។ សុខអាចប្រគល់សិទ្ធិលើទ្រព្យសម្បត្តិនេះ(ឡាន)ទៅឲ្យតតិយជនក្នុងការធ្វើការចាត់ចែងទ្រព្យសម្បត្តិដោយឡែកនេះជំនួសខ្លួនបានផងដែរ តាមរយៈកិច្ចសន្យាដែលមានការព្រមព្រៀងពីភាគីទាំងសងខាងដោយមិនបាច់មានការយល់ព្រមពីប្រពន្ធ។

ទ្រព្យសម្បត្តិដោយឡែកនេះ គឺស្ថិតនៅក្រោមការប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងពីសំណាក់សហព័ទ្ធតែម្ខាងប៉ុណ្ណោះ មានន័យថាសហព័ទ្ធម្ខាងទៀតមិនអាចទទួលបាននូវសិទ្ធិទាំងនេះបានទេ ប្រសិនបើគ្មានការអនុញ្ញាតពីសហព័ទ្ធជាម្ចាស់កម្មសិទ្ធិ។

❖ **ចំណាំ:** *សហព័ទ្ធណាម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដែលទ្រព្យសម្បត្តិដោយឡែកនេះត្រូវប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ ក្នុងករណីដែលសហព័ទ្ធដែលជាកម្មសិទ្ធិករបានធ្វើការចាត់ចែងលើអចលនវត្ថុនោះក៏ដោយសហព័ទ្ធម្ខាងទៀតក៏អាចបន្តអាស្រ័យនៅលើអចលនវត្ថុនោះបានដែរ។*[41]

ក្នុងករណីនេះ ប្រសិនបើសហព័ទ្ធណាម្ខាងដែលមានទ្រព្យសម្បត្តិដោយឡែកដែលជាអចលនវត្ថុក្នុងការអាស្រ័យនៅបាន ហើយសហព័ទ្ធម្ខាងទៀតគ្មានទីជម្រកក្នុងការអាស្រ័យនៅ សហព័ទ្ធដែលគ្មានទីជម្រក អាចធ្វើការអាស្រ័យនៅលើអចលនវត្ថុដែលជាទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀតបាន។ ដោយករណីនេះសហព័ទ្ធដែលមានទ្រព្យសម្បត្តិនោះមិនអាចធ្វើការបដិសេធមិនឲ្យសហព័ទ្ធម្ខាងទៀតអាស្រ័យនៅជាមួយខ្លួនបាននោះទេ។ ឧទាហរណ៍៖ បុរស "ក" (ប្តី)មានផ្ទះមួយកន្លែងនៅទីក្រុងភ្នំពេញ ហើយនារី "ខ" (ប្រពន្ធ)គ្មានទីកន្លែងក្នុងការអាស្រ័យនៅ។ ដូចនេះ នារី "ខ" (ប្រពន្ធ)អាចធ្វើការមកស្នាក់នៅជាមួយបុរស "ក" (ប្តី)បានផងដែរ។

## ១.២. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ [42] មានន័យថា ក្នុងអំឡុងអាពាហ៍ពិពាហ៍រាល់ទ្រព្យសម្បត្តិដែលកើតឡើងក្នុងពេលនោះ ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួម។ លើកលែងតែទ្រព្យនោះកើតចេញពី ប្រទានកម្ម សន្តតិកម្ម អច្ច័យទានតែប៉ុណ្ណោះ ដែលគេបានចាត់ថាជាទ្រព្យសម្បត្តិដោយឡែកដូចខាងលើនេះ។

### ១.២.១. ប្រភពនៃទ្រព្យរួម

ប្រភពនៃទ្រព្យសម្បត្តិរួម គឺបញ្ជាក់អំពីទ្រព្យសម្បត្តិដែលត្រូវបានកើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដោយទ្រព្យសម្បត្តិរបស់សហព័ទ្ធនេះត្រូវបានរាប់បញ្ចូល៖

– ទ្រព្យសម្បត្តិដែលកើតចេញពីការងាររបស់សហព័ទ្ធ ។

[41] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៧។

[42] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

– ផលដែលបានកើតចេញពីទ្រព្យសម្បត្តិរួម។ ដែលផលទាំងនោះជាផលធម្មជាតិ និងផលស៊ីវិល។

- ផលធម្មជាតិ៖ គឺសំដៅទៅលើចំណូលដែលកើតឡើងដោយឯកឯងតាមធម្មជាតិដូចជា ដើមឈើ សត្វ...។ល។

- ផលស៊ីវិល៖ គឺសំដៅទៅលើចំណូលដែលទទួលបានតាមរយៈការគ្រប់គ្រងដោយប្រយោល លើទ្រព្យសម្បត្តិនោះ ដូចជាប្រាក់ឈ្នួលផ្ទះ កម្រៃនៃការប្រវាស់ដី ឬ ការប្រាក់...។ល។

រាល់ទ្រព្យសម្បត្តិទាំងអស់ខាងលើនេះ ដែលបានកកើតក្នុងអំឡុងពេលមានចំណង អាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិរួម។

### ១.២.២. ការគ្រប់គ្រងទ្រព្យសម្បត្តិរួម

ការគ្រប់គ្រងទ្រព្យសម្បត្តិរួម គឺជាសិទ្ធិរបស់សហព័ទ្ធទាំងសងខាង ឬសិទ្ធិរបស់ប្តីប្រពន្ធក្នុងការ គ្រប់គ្រងទ្រព្យសម្បត្តិ។ ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម។ [43] ប្តីឬប្រពន្ធមានសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិរួមនេះដោយមិន ចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតនោះទេ ប្រសិនបើគោលបំណងនៃការប្រើប្រាស់នោះគឺ សំរាប់ភាពចាំបាច់ក្នុងជីវភាពគ្រួសារដូចជា ការទិញម្ហូបអាហារ ការទិញសម្ភារៈក្នុងផ្ទះ ការបង់នូវ ថ្លៃសាលារៀនរបស់កូន...។

ចំណែកឯការគ្រប់គ្រងទ្រព្យសម្បត្តិនេះផងដែរ ប្តីប្រពន្ធត្រូវធ្វើការគ្រប់គ្រង ដោយសហការគ្នា មានន័យថា ប្តីប្រពន្ធត្រូវចូលរួមចំណែកគ្នាក្នុងការមើលថែរក្សា ឬ ថែទាំលើទ្រព្យសម្បត្តិនោះដើម្បី ជៀសវាងនូវការខូចខាត ឬ ការបាត់បង់តម្លៃនៃទ្រព្យសម្បត្តិនោះ។ ការគ្រប់គ្រងនេះអាចនឹង ត្រូវបានទាមទារនូវសោហ៊ុយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនេះ ដូច្នេះហើយ ប្តីប្រពន្ធទាំងសងខាង ត្រូវទទួលខុសត្រូវស្មើគ្នាក្នុងការចេញនូវសោហ៊ុយដើម្បីធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិនេះ។

ឧទាហរណ៍៖ ប្តីប្រពន្ធបានជួលបុរសម្នាក់ក្នុងការមើលថែទាំដីមួយកន្លែងរបស់ពួកគេដែលស្ថិត នៅក្នុងខេត្តរតនៈគិរី ដោយបានផ្តល់នូវប្រាក់ឈ្នួលដល់បុរសនោះ ក្នុង១ខែ ២០០ ដុល្លារអាមេរិច។

[43] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៤។

ដូច្នេះ ប្តីនិងប្រពន្ធត្រូវចេញនូវសោហ៊ុយស្មើគ្នាក្នុងការធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរួមនោះ។ ក្នុងករណីដែលទ្រព្យសម្បត្តិរួមនេះអាចផ្តល់នូវផលតបស្នង នោះសហាព័ទ្ធទាំងសងខាងនឹងត្រូវបានទទួលនូវផលចំណែកនោះស្មើៗគ្នាផងដែរ។ ឧទាហរណ៍៖ ប្តីប្រពន្ធមានចំការធុរេនមួយកន្លែងនៅខេត្តកំពត ដែលចំការធុរេននេះបានផ្តល់នូវផលប្រយោជន៍ដល់ពួកគេក្នុងមួយរដូវបាន៥០០០ដុល្លារអាមេរិច។ ដូចនេះ ផលដែលបានមកពីការទទួលនូវផលពីចំការនោះសហាព័ទ្ធត្រូវទទួលបានចំណែកស្មើគ្នា។

ក៏ប៉ុន្តែក្នុងករណីដែលសហាព័ទ្ធណាម្ខាងធ្វើការមិនសុខចិត្ត ឬ ជំទាស់ពីការគ្រប់គ្រង ឬការប្រើប្រាស់ទ្រព្យសម្បត្តិរួមនេះ ដោយយល់ឃើញថាខ្លួនទទួលបាននូវសិទ្ធិ ឬ ផលប្រយោជន៍តិចជាងសហាព័ទ្ធម្ខាងទៀត សហាព័ទ្ធដែលមិនសុខចិត្តនោះអាចធ្វើការទាមទារទៅតុលាការដើម្បីសុំឲ្យធ្វើការបែងចែកសមត្ថកិច្ចក្នុងការចាត់ចែង ឬ ប្រើប្រាស់លើទ្រព្យសម្បត្តិរួមនោះបាន ។

### ១.២.៣. ការចាត់ចែងទ្រព្យសម្បត្តិរួម

ជាគោលការណ៍ សហាព័ទ្ធទាំងសងខាងត្រូវធ្វើការចាត់ចែងរួមគ្នាលើទ្រព្យសម្បត្តិរួមនេះ មានន័យថាការចាត់ចែងទ្រព្យសម្បត្តិនេះអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីសហាព័ទ្ធទាំងសងខាង។ ក៏ប៉ុន្តែក្នុងករណីដែលមានភាពចាំបាច់ក្នុងការថែទាំ និងរក្សាជីវភាពរស់នៅរបស់សហាព័ទ្ធនោះ ប្តីឬប្រពន្ធមានសិទ្ធិក្នុងការធ្វើការចាត់ចែង ឬ លក់ដោយមិនចាំបាច់មានការយល់ព្រមពីសហាព័ទ្ធម្ខាងទៀតនោះទេ តែត្រូវមានការអនុញ្ញាតពីតុលាការក្នុងការធ្វើការចាត់ចែងទ្រព្យសម្បត្តិរួមនេះ។ ឧទាហរណ៍៖ នារី "ខ" (ប្រពន្ធ)បានយកម៉ូតូមួយគ្រឿង (ទ្រព្យសម្បត្តិរួម)ទៅបញ្ចាំដើម្បីយកប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារដូចជា បង់ថ្លៃសិក្សា ទិញសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ទិញម្ហូបអាហារ...។ល។ ផ្ទុយទៅវិញ ប្រសិនបើប្តីឬប្រពន្ធបានធ្វើការលក់ទ្រព្យសម្បត្តិរួមដោយគ្មានការយល់ព្រមពីសហាព័ទ្ធម្ខាងទៀត និង គ្មានការអនុញ្ញាតពីតុលាការផង សហាព័ទ្ធដែលមិនបានយល់ព្រមនោះមានសិទ្ធិក្នុងការទាមទារឲ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការបាន នៅក្នុងអំឡុងពេល២ឆ្នាំ គិតចាប់ពីពេលដែលដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុ និង នៅក្នុងអំឡុងពេល១ឆ្នាំ គិតចាប់ពីពេលដែលបានដឹងពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិនោះជាចលនវត្ថុ។[44] ក្នុងករណីនេះ ប្រសិនបើសហាព័ទ្ធបានដឹងពីការចាត់ចែងនេះ ហើយខ្លួនបានធ្វើប្រងើយកណ្តើយនឹងការចាត់ចែងនោះ ដោយមិនបានធ្វើការ

[44] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៦។

ប្ដឹងទៅតុលាការក្នុងការទាមទារឲ្យលុបចោលការចាត់ចែងនោះ ក្នុងអំឡុងពេលដែលច្បាប់បានកំណត់ខាងលើនោះទេ មានន័យថាសហព័ទ្ធដែលមិនបានធ្វើការយល់ព្រមពីការចាត់ចែងនោះត្រូវចាត់ទុកថាបានយល់ព្រមលើសកម្មភាពរបស់សហព័ទ្ធម្ខាងទៀត ដែលបានចាត់ចែងទ្រព្យសម្បត្តិនោះ។

## ផ្នែកទី២ ការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យរបស់សហព័ទ្ធតាមច្បាប់កំណត់

ក្រោយពីបានសិក្សាពីប្រភេទនៃទ្រព្យសម្បត្តិ ក៏ដូចជាសិទ្ធិក្នុងការគ្រប់គ្រង និង ការចាត់ចែងលើទ្រព្យសម្បត្តិរួចហើយ យើងគប្បីស្វែងយល់ពីការបញ្ចប់នូវប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលច្បាប់បានកំណត់នេះផងដែរ ព្រោះថាសហព័ទ្ធគ្រប់រូបគឺមិនអាចស្មានដឹងថានឹងអាចមានរឿងអ្វីដែលអាចនឹងកើតមានឡើង ក្នុងជីវិតអាពាហ៍ពិពាហ៍របស់ខ្លួននោះទេ។ ហេតុការណ៍ដែលអាចកើតឡើងនោះ ក៏អាចមានអានុភាពក្នុងការបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេផងដែរ។ ដូច្នេះ តើការបញ្ចប់ចំណងអាពាហ៍ពិពាហ៍នឹងអាចមានឥទ្ធិពលអ្វីខ្លះទៅលើប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់?

### ២.១. មូលហេតុនៃការបញ្ចប់ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិសហព័ទ្ធ

ជាការពិតណាស់ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធនេះគឺត្រូវបានកកើតឡើងពីចំណងអាពាហ៍ពិពាហ៍ ដែលអាចនិយាយបានថា ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ គឺត្រូវបានផ្សាភ្ជាប់ជាមួយនឹងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់មួយ។ ការកកើតចំណងអាពាហ៍ពិពាហ៍នេះបានផ្ដល់នូវសិទ្ធិ និងកាតព្វកិច្ចទៅដល់សហព័ទ្ធទាំងសងខាងក្នុងការគ្រប់គ្រង ថែរក្សា និងធ្វើការចាត់ចែងទ្រព្យសម្បត្តិទាំងនេះ ដោយប្រកបដោយភាពសុចរិតស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក។ ក៏ប៉ុន្តែអាពាហ៍ពិពាហ៍មួយ ក៏អាចឈានទៅដល់ការបញ្ចប់ផងដែរ ដោយមានមូលហេតុមួយចំនួន ដូចជា ការលែងលះ ការបាត់ខ្លួន មរណភាព មោឃភាពអាពាហ៍ពិពាហ៍ជាដើម។ ទាំងអស់នេះហើយ ដែលជាហេតុដែលនាំឲ្យប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់នេះក៏នឹងត្រូវបានបញ្ចប់ផងដែរ។ ដូច្នេះ យើងនឹងសិក្សាអំពីមូលហេតុផ្សេងៗគ្នា ដែលនាំឲ្យមានការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់នេះនៅចំណុចខាងក្រោម។

### ២.១.១. ការលែងលះ

ជាការពិតណាស់ ចំណងអាពាហ៍ពិពាហ៍អាចនឹងត្រូវបានកាត់ផ្តាត់ ប្រសិនបើសហព័ទ្ធណាម្ខាងបានបង្ហាញឆន្ទៈមិនអាចរួមរស់ជាមួយគ្នាសហព័ទ្ធម្ខាងទៀតបាន ឬក៏មកពីកំហុសរបស់សហព័ទ្ធណាម្ខាង ដែលជាហេតុនាំឲ្យចំណងអាពាហ៍ពិពាហ៍មិនអាចបន្តទៀតបាន។

ការលែងលះនេះគឺអាចធ្វើទៅបានតាមពីរបែបគឺ ការដាក់ពាក្យបណ្តឹងសុំលែងលះ និងការលែងលះដោយមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង។

– ការដាក់ពាក្យបណ្តឹងលែងលះ គឺជាការប្តឹងទាមទារពីសហព័ទ្ធណាម្ខាងដោយ ត្រូវភ្ជាប់ជាមួយមូលហេតុត្រឹមត្រូវដែលមានចែងក្នុងក្រមរដ្ឋប្បវេណី មាត្រា ៩៧៦។ មូលហេតុនោះមានដូចជា៖

- អំពើផិត៖ ក្នុងករណីដែលសហព័ទ្ធណាម្ខាងបានប្រព្រឹត្តនូវអំពើផិតក្បត់ទៅលើសហព័ទ្ធម្ខាងទៀត សហព័ទ្ធម្ខាងទៀតមានសិទ្ធិក្នុងការដាក់បណ្តឹងទៅតុលាការដើម្បីធ្វើការលែងលះបាន។ ឧទាហរណ៍៖ ប្តីបានធ្វើការសេពសន្ថវៈជាមួយនារីដទៃក្រៅពីប្រពន្ធរបស់ខ្លួន នៅពេលដែលប្រពន្ធដឹងពីរឿងនេះប្រពន្ធមានសិទ្ធិក្នុងការប្តឹងលែងលះទៅតុលាការ ដើម្បីបញ្ចប់ចំណងអាពាហ៍ពាហ៍នេះបាន។

- ការបោះបង់សហព័ទ្ធ៖ ប្រសិនបើសហព័ទ្ធណាម្ខាងបានធ្វើការបោះបង់សហព័ទ្ធម្ខាងទៀងដោយមិនបានប្រាប់ពីមូលហេតុនៃការបោះបង់នោះ សហព័ទ្ធដែលត្រូវបានគេបោះបង់អាចធ្វើការដាក់បណ្តឹងក្នុងការធ្វើការលែងលះបាន។ ឧទាហរណ៍៖ ប្តីបានចាកចេញមករស់នៅភ្នំពេញ ដោយមិនបានប្រាប់ពីមូលហេតុ ហើយបានទុកប្រពន្ធចោលនៅខេត្តបាត់ដំបងឲ្យរស់នៅម្នាក់ឯងអស់រយៈពេលជាច្រើនឆ្នាំ។

- ការបាត់ខ្លួនរបស់សហព័ទ្ធណាម្ខាង៖ ក្នុងករណីដែលសហព័ទ្ធណាម្ខាងបានបាត់ខ្លួនដោយសហព័ទ្ធម្ខាងទៀតមិនដឹងច្បាស់ថាតើសហព័ទ្ធរបស់ខ្លួនរស់ ឬ ស្លាប់ អស់រយៈពេលជាង ១ ឆ្នាំ សហព័ទ្ធដែលមិនដឹងច្បាស់នោះ អាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន។ ឧទាហរណ៍៖ ប្តីបានចាកចេញពីប្រពន្ធទៅកាន់កន្លែងមួយ ហើយបន្ទាប់មកប្រពន្ធមិនដែលទទួលបានព័ត៌មានអ្វីដែលទាក់ទងពីប្តីរបស់គេអស់រយៈពេលជាង១ឆ្នាំ

ដូចនេះតុលាការអាចចេញសាលក្រមលែងលះឲ្យប្រពន្ធបាន ប្រសិនបើករណីនេះបានកើតឡើង។

- ការរស់នៅបែកគ្នាជាបន្តបន្ទាប់៖ ក្នុងករណីដែលសហព័ទ្ធទាំងពីរគឺបានធ្វើការរស់នៅបែកគ្នាជាបន្តបន្ទាប់ដោយហេតុថាមានជម្លោះជាមួយគ្នា ឬ មិនចុះសម្រុងគ្នាអស់រយៈពេលជាងមួយឆ្នាំ សហព័ទ្ធម្ខាងមានសិទ្ធិដាក់ពាក្យបណ្ដឹងលែងលះបានដោយអាចលើកឡើងថា វាផ្ទុយទៅនឹងបំណងនៃអាពាហ៍ពិពាហ៍។ ឧទាហរណ៍៖ ដោយមានជម្លោះជាមួយគ្នា សហព័ទ្ធទាំងសងខាងបានរស់នៅដាច់ពីគ្នា ប្រពន្ធបានទៅរស់នៅជាមួយឪពុកម្ដាយ ប្ដីបានធ្វើការស្នាក់នៅជាមួយបងប្អូនអស់រយៈពេលជាង ១ ឆ្នាំសកម្មភាពនេះនៅតែបន្តបន្ទាប់ដោយគ្មានការផ្សះផ្សាមួយណាអាចធ្វើជាដំណោះស្រាយបាន។

- ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់៖ ក្នុងករណីដែលចំណងអាពាហ៍ពិពាហ៍ឈានដល់ការបែកបាក់ក្នុងស្ថានភាពធ្ងន់ធ្ងរ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើការផ្សះផ្សាវិញបាន នោះសហព័ទ្ធណាម្ខាងមានសិទ្ធិក្នុងដាក់ពាក្យបណ្ដឹងសុំលែងលះទៅតុលាការបាន ដោយបញ្ជាក់ពីមូលហេតុពីការនៃការបែកបាក់នោះទៅតុលាការ។ ឧទាហរណ៍៖ ប្ដីតែងតែទទួលទានគ្រឿងស្រវឹង ហើយពេលមកដល់ផ្ទះតែងរករឿងឈ្លោះគ្នាជាមួយប្រពន្ធដោយមិនឲ្យប្រពន្ធបានសម្រាក។

– ការលែងលះដោយមានការយល់ព្រមពីសហព័ទ្ធ គឺសំដៅទៅលើភាគីនៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា។ [45] អាពាហ៍ពិពាហ៍មួយក៏ត្រូវបានបញ្ចប់ ប្រសិនបើសហព័ទ្ធទាំងសងខាងយល់ឃើញថា ពួកគេមិនអាចបន្តការរស់នៅជាប្ដីប្រពន្ធជាមួយគ្នាបានតទៅទៀតបាននោះទេ ដូចនេះពួកគេអាចដាក់ពាក្យប្ដឹងឲ្យតុលាការសុំឲ្យចេញនូវសេចក្ដីសម្រេចចំពោះការលែងលះរបស់ពួកគេបាន។ ឧទាហរណ៍៖ លោក "ក" និង នាង "ខ" បានព្រមព្រៀងគ្នាក្នុងការបញ្ចប់ជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ។

ប៉ុន្តែតុលាការនឹងមិនសម្រេចឲ្យសហព័ទ្ធលែងលះបានទេ ប្រសិនបើសហព័ទ្ធទាំងសងខាងមិនបង្ហាញពីគោលបំណងច្បាស់លាស់ក្នុងការបញ្ចប់ចំណងអាពាហ៍ពិពាហ៍នោះទេ។

[45] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៩។

### ២.១.២. មរណភាព និងការបាត់ខ្លួន

មរណភាពរបស់សហព័ទ្ធណាម្ខាងក៏ជាមូលហេតុមួយ ក្នុងការឈានទៅដល់ការបញ្ចប់ចំណង អាពាហ៍ពិពាហ៍មួយផងដែរ។ ព្រោះយើងបានដឹងហើយថាចំណងអាពាហ៍ពិពាហ៍គឺត្រូវកើតមាន ឡើងរវាងបុរសម្នាក់ និងនារីម្នាក់ដោយមានការស្ម័គ្រចិត្តក្នុងការរួមរស់ជាមួយគ្នា។ ដូច្នេះក្នុងករណី ប្រសិនបើចំណងអាពាហ៍ពិពាហ៍នោះមានសហព័ទ្ធតែម្ខាង ដោយសហព័ទ្ធម្ខាងទៀតត្រូវបាន ទទួលមរណភាព នោះចំណងអាពាហ៍ពិពាហ៍ក៏ត្រូវបានធ្វើការបញ្ចប់ផងដែរ ព្រោះចំណង អាពាហ៍ពិពាហ៍មួយមិនអាចមានតែសហព័ទ្ធតែម្ខាងនោះទេ។

ការបាត់ខ្លួន គឺសំដៅទៅលើការអវត្តមានសហព័ទ្ធណាម្ខាង ក្នុងរយៈពេលមួយដែលច្បាប់បាន កំណត់ទុកជាស្រេច។ ប្រសិន បើការបាត់ខ្លួនរបស់សហព័ទ្ធនេះ គ្មាននរណាម្នាក់ បានដឹងពីដំណឹង ច្បាស់លាស់ថា តើបុគ្គលនោះនៅមានជីវិត ឬ ត្រូវបានទទួលមរណភាព តុលាការអាចធ្វើការ ប្រកាសពីការបាត់ខ្លួនរបស់បុគ្គលម្នាក់នោះបាន ប្រសិនពុំមានដំណឹងច្បាស់លាស់ ថាអ្នកអវត្តមាន នៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ៥ ឆ្នាំ។ ស្របគ្នានេះដែរ ប្រសិនបើក្នុងករណី ដែលបុគ្គលចូលទៅតំបន់ដែលមានគេបានដឹងច្បាស់លាស់ ដូចជា ការធ្វើសង្គ្រាម ការជិះកប៉ាល់ ហើយពុំមានដំណឹងច្បាស់លាស់ថាបុគ្គលនោះនៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ១ ឆ្នាំ។ អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាព។[46] ដូចនេះ ដោយមូលហេតុនៃការបាត់ខ្លួនក៏ អាចបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍បានផងដែរ។

ហេតុនេះ មរណភាព និង ការបាត់ខ្លួនក៏ជាមូលហេតុនាំឲ្យមានការបញ្ចប់នូវចំណង អាពាហ៍ពិពាហ៍ ក៏ដូចជាការបញ្ចប់នូវប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់ កំណត់ផងដែរ។ ព្រោះយើងបានដឹងហើយថាប្រព័ន្ធនេះគឺត្រូវបានកើតឡើងពីចំណងអាពាហ៍ ពិពាហ៍ ដូចនេះប្រសិនបើគ្មានចំណងអាពាហ៍ពិពាហ៍កើតមានឡើងនោះទេ ប្រព័ន្ធនៃការគ្រប់គ្រង នេះក៏មិនអាចកើតមានឡើងដូចគ្នាដែរ។

ប្រសិនបើមានសហព័ទ្ធណាម្ខាងបានទទួលមរណភាព ឬ បាត់ខ្លួន ក្រោយពីប្រព័ន្ធគ្រប់គ្រង ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់ត្រូវបានបញ្ចប់ ដែលជាហេតុមួយនាំឲ្យមានការបែង ចែកទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក។ ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ គឺ

[46] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៣។

ទទួលបានចំណែកទ្រព្យសម្បត្តិរៀងៗខ្លួន។ រីឯទ្រព្យសម្បត្តិរួមវិញ ត្រូវបានបែងចែកចេញជាពីរចំណែកដោយសហព័ទ្ធដែលនៅរស់ទទួលបានមួយចំណែក ព្រមទាំងមួយចំណែកទៀតត្រូវបានធ្វើសន្តតិកម្មទៅឲ្យញាតិរបស់មតកជននោះដែលបានកំណត់ដោយច្បាប់។ តើអ្វីទៅជាសន្តតិកម្ម? តើលំដាប់ថ្នាក់សន្តតិជនណាខ្លះ ទើបអាចទទួលបានមរតក?

សន្តតិកម្មត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន។[47] សន្តតិកម្មនេះត្រូវបានបែងចែកជាពីរប្រភេទគឺ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមបណ្តាំ។ ការបែងចែកសន្តតិកម្មតាមបណ្តាំគឺជាការបែងចែកមរតកទៅតាមឆន្ទៈរបស់មកតជនដែលបានធ្វើឡើងមុនពេលស្លាប់។ ឯសន្តតិកម្មតាមច្បាប់វិញ គឺត្រូវធ្វើឡើងទៅតាមលំដាប់សន្តតិកម្មដែលមានចែងនៅក្នុងច្បាប់ដែលបានកំណត់នូវលំដាប់ថ្នាក់សន្តតិជនក្នុងការទទួលយកនូវមរតករបស់មតកជនដែលមាន។ ការបែងចែកទ្រព្យសម្បត្តិដោយឡែកតាមរយៈនេះ គឺត្រូវបានបែងចែកទៅតាមលំដាប់ថ្នាក់សន្តតិជនដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ក្រមនេះបានធ្វើការបែងចែកលំដាប់ថ្នាក់សន្តតិជនជាបីថ្នាក់៖

- លំដាប់ថ្នាក់ទីមួយ៖ គឺសំដៅទៅលើកូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនស្មុំក្តីត្រូវទទួលបានចំណែកស្មើៗគ្នា។[48]

- លំដាប់ថ្នាក់ទីពីរ៖ ក្នុងករណីដែលមតកជនមិនមានបច្ឆាញាតិនោះទេ នោះបុព្វញាតិរបស់មតកជននឹងក្លាយជាសន្តតិជន ប៉ុន្តែត្រូវយកបុព្វញាតិដែលនៅជិតជាងជាមុន ប្រសិនបើបុព្វញាតិ ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលបានចំណែកមរតកស្មើៗគ្នា។[49]

- លំដាប់ថ្នាក់ទីបី៖ ក្នុងករណីដែលមតកជនពុំមានទាំងបច្ឆាញាតិ និងបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះត្រូវក្លាយជាសន្តតិជន។[50]

[47] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៥។

[48] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៦។

[49] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៩។

[50] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦០។

ចំណែកសហាព័ទ្ធដែលនៅរស់របស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។[51]

## ២.១.៣. មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍មួយ ក៏អាចឈានដល់ការមោឃភាព និងការលុបចោលផងដែរ ប្រសិនបើគេរកឃើញនូវចំណុច ឬ គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍នោះបានប្រព្រឹត្តផ្ទុយពីឆន្ទៈសហាព័ទ្ធណាម្ខាង ឬ មានវិការៈធ្ងន់ធ្ងរលើនីតិវិធីរៀបអាពាហ៍ពិពាហ៍។

មោឃភាពដោយផ្ទុយពីឆន្ទៈរបស់សហាព័ទ្ធ៖ ក្នុងករណីបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍រវាងភាគី ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងៗទៀត។ [52]

- ការភ័ន្តច្រឡំលើមនុស្ស៖ ក្នុងករណីនេះ ភាគីមានគោលបំណងក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀត ក៏ប៉ុន្តែដោយមានការភ័ន្តច្រឡំមនុស្សក៏បានទៅរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀត ដែលគ្រាន់តែមានរូបរាងដូចនឹងភាគីដែលខ្លួនគម្រោងនឹងធ្វើការរៀបការជាមួយប៉ុណ្ណោះ នេះជាហេតុនាំឲ្យមានការមោឃភាពអាពាហ៍ពិពាហ៍កើតមានឡើងនៅពេលដែលខ្លួនដឹងថា អាពាហ៍ពិពាហ៍នេះមានការភ័ន្តច្រឡំលើមនុស្ស។ ឧទាហរណ៍៖ បុរស "ក" បាននឹងធ្វើការរៀបការជាមួយនារី "ខ" នៅថ្ងៃជាក់លាក់ណាមួយ។ ដោយនារី "ខ" មានប្អូនស្រីឈ្មោះ នារី "គ" ដែលត្រូវជាកូនភ្លោះជាមួយនឹងខ្លួន។ ដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ បុរស "ក" បានរកឃើញថាខ្លួនមិនបានរៀបការជាមួយនារី "ខ" ទេ តែការរៀបការនោះគឺជាមួយនឹងនារី "គ" ទៅវិញ។ ដូចនេះហើយ ករណីនេះបុរស "ក" អាចមានសិទ្ធិក្នុងការសុំឲ្យមោឃភាពអាពាហ៍ពិពាហ៍នេះបាន។

- ការបង្ខំ៖ ក្នុងករណីអាពាហ៍ពិពាហ៍មួយត្រូវបានកើតឡើងដោយមានការបង្ខិតបង្ខំពីសំណាក់ឪពុកម្តាយ អាណាព្យាបាល ឬ តតិយជន ក្នុងការឲ្យភាគីម្ខាងនៃចំណងអាពាហ៍ពិពាហ៍នោះ ធ្វើការយល់ព្រមរៀបអាពាហ៍ពាហ៍ជាមួយភាគីម្ខាងទៀត។ ដោយយើងបានដឹងហើយថាចំណង់អាពាហ៍ពិពាហ៍មួយស្របច្បាប់គឺត្រូវ

[51] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦១។

[52] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៨។

ធ្វើឡើងដោយមានការយល់ព្រមចេញពីឆន្ទៈរវាងភាគីទាំងសងខាង ប្រសិនបើភាគីណាម្ខាងមិនបានយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍នោះទេ ហើយដោយហេតុថាមានការបង្ខំឲ្យធ្វើការយល់ព្រមពីសំណាក់បុគ្គលណាមួយ ក្នុងការយល់ព្រមឲ្យរៀបការនោះ អាពាហ៍ពិពាហ៍នោះអាចត្រូវធ្វើការមោឃភាពបាន។ ឧទាហរណ៍៖ នារី "ខ" មិនបានស្រលាញ់បុរស "ក" ទេ ក៏ប៉ុន្តែដោយសារការបង្ខិតបង្ខំពីសំណាក់ឪពុកម្ដាយរបស់នាង ដោយមានការធ្វើបាបលើរូបរាងកាយ ឬ ការបង្អត់អាហារជាដើម។ ហេតុនេះទើបនាងបានធ្វើការយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយបុរស "ក" នោះ។ ករណីបែបនេះ តុលាការអាចធ្វើការមោឃភាពអាពាហ៍ពិពាហ៍នោះ ហើយអាចមានការផ្ដន្ទាទោសដល់ឪពុកម្ដាយពីបទហិង្សាដោយចេតនាផងដែរ។

– មោឃភាពដោយមានវិការៈធ្ងន់ធ្ងរ៖ ប្រសិនបើភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍។[53]

- អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយមានការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[54] ក្នុងករណីដែលភាគីនៃអាពាហ៍ពិពាហ៍មិនបានធ្វើតាមនីតិវិធីខាងលើទេ នោះច្បាប់មិនទទួលស្គាល់ថានេះជាការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ គេចាត់ទុកវាគឺជាវិធីជប់លៀងមួយធម្មតាប៉ុណ្ណោះ។ ក្នុងករណីដែលនីតិវិធីខាងលើបានភ្ជាប់ជាមួយនឹងវិការៈធ្ងន់ធ្ងរ ច្បាប់ក៏នឹងធ្វើការមោឃភាពលើអាពាហ៍ពិពាហ៍នោះផងដែរ។

ការលុបចោលអាពាហ៍ពិពាហ៍នឹងអាចធ្វើឡើង ប្រសិនបើគេរកឃើញថាអាពាហ៍ពាហ៍នោះមានវិការៈដូចជា៖

[53] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៨។

[54] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៥។

- អាយុ៖ បុរស និង នារី ដែលមិនទាន់ដល់នីតិភាពមិនអាចធ្វើការរៀបអាពាហ៍ពិពាហ៍បានឡើយ។[55] ប៉ុន្តែប្រសិនបើ បុរស ឬ នារីដែលមានអាយុមមិនតិចជាង១៦ឆ្នាំ អាចធ្វើការរៀបអាពាហ៍ពិពាហ៍បាន ប្រសិនបើមានការយល់ព្រមពីឪពុកម្តាយ ឬ អ្នកដែលមានអំណាចអាណាព្យាបាល។ ឧទាហរណ៍៖ បុរសមានអាយុ ១៨ ឆ្នាំ មានបំណងក្នុងការរៀបការជាមួយនារីដែលមានអាយុ ១៥ ឆ្នាំ ដោយអាពាហ៍ពិពាហ៍នេះបានប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ដែលបានកំណត់ អាពាហ៍ពិពាហ៍នេះអាចធ្វើការលុបចោលបាន។

- ទ្វេពន្ធភាព៖ បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចធ្វើការរៀបអាពាហ៍ពិពាហ៍ទៀតបានទេ។[56] ប្រសិនបើអាពាហ៍ពិពាហ៍ចាស់មិនត្រូវបានបញ្ចប់ជាស្ថាពរទេ សហព័ទ្ធមិនអាចធ្វើការរៀបអាពាហ៍ពិពាហ៍ថ្មីបានទេ។ ឧទាហរណ៍៖ បុរស "ក" ជាសហព័ទ្ធស្របច្បាប់ជាមួយ នារី "ខ" នៅភ្នំពេញ។ បុរស "ក" ក៏បានធ្វើការរៀបអាពាហ៍ពិពាហ៍ម្តងទៀត ជាមួយនារី "គ" នឹងបានចុះសំបុត្រអាពាហ៍ពិពាហ៍ម្តងទៀតនៅខេត្តបាត់ដំបង។ ដូចនេះនារី "ក" អាចប្តឹងឲ្យលុបចោលអាពាហ៍ពិពាហ៍រវាងបុរស "ក" ជាមួយនារី "គ" បាន។

- ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត៖ នៅពេលដែលចំណងអាពាហ៍ពិពាហ៍មួយត្រូវបានកាត់ផ្តាច់ នារីមិនអាចធ្វើការរៀបការថ្មីបានទេ ប្រសិនបើអំឡុងពេល ១២០ ថ្ងៃ មិនទាន់បានកន្លងផុត។[57] ក្នុងករណីដែលនារីនោះបានធ្វើការរៀបអាពាហ៍ពិពាហ៍ថ្មីដែលផ្ទុយពីច្បាប់ នោះសហព័ទ្ធមុនអាចធ្វើការប្តឹងក្នុងការលុបចោលនូវអាពាហ៍ពិពាហ៍ថ្មីនោះបាន។ ឧទាហរណ៍៖ ក្រោយពីបានបញ្ចប់ចំណងអាពាហ៍ពិពាហ៍ជាមួយបុរស "ក" អស់រយៈពេល ៣០ ថ្ងៃ នារី "ខ" ក៏បានធ្វើការរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយបុរស "គ"។ ករណីនេះ បុរស "ក" មានសិទ្ធិក្នុងការប្តឹងលុបចោលអាពាហ៍ពិពាហ៍ថ្មីនោះបាន។

- ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត៖ អាពាហ៍ពិពាហ៍មិនអាចធ្វើឡើង រវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិត ៣ ថ្នាក់រាប់ទាំងថ្នាក់ទី៣

[55] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨។

[56] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៩។

[57] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥០។

ផង។[58] ឧទាហរណ៍៖ បុរស "ក" និងនារី "ខ" ដែលត្រូវជាបងប្អូនបង្កើតជាមួយគ្នា មិនអាចធ្វើការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាននោះទេ។

– ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយរវាងញាតិពន្ធ៖ អាពាហ៍ពិពាហ៍ពុំអាចធ្វើទៅបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់។[59] ឧទាហរណ៍៖ បុរស "ក" បានរៀបអាពាហ៍ពិពាហ៍ជាមួយនារី "ខ" (ប្រពន្ធ) បន្ទាប់មកចំណងអាពាហ៍ពិពាហ៍នេះក៏ត្រូវបានកាត់ផ្តាច់ដោយសារការលែងលះ ដូច្នេះបុរសមិនអាចធ្វើការរៀបអាពាហ៍ពាហ៍ថ្មីជាមួយប្អូនស្រីរបស់នារី "ខ" បាននោះ ទេ។

ក្រោយពីបានសិក្សាអំពីមូលហេតុដែលនាំឲ្យប្រព័ន្ធនៃការគ្រប់គ្រងសម្បត្តិរបស់សហព័ទ្ធត្រូវបានបញ្ចប់ យើងនឹងធ្វើការសិក្សាបន្ថែមថា តើការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធត្រូវបានធ្វើការបែងចែកយ៉ាងដូចម្តេច?

## ២.២. ការបែងចែកទ្រព្យសម្បត្តិរបស់សហព័ន្ធ

ការបែងចែកទ្រព្យសម្បត្តិគឺជាទិដ្ឋភាពមួយដែលសហព័ទ្ធទាំងឡាយមិនប្រាថ្នាចង់បាន ដោយហេតុថា ការបែងចែកទ្រព្យសម្បត្តិនេះគឺត្រូវផ្សាភ្ជាប់ជាមួយមូលហេតុមួយចំនួន ដែលធ្វើឲ្យមានផលប៉ះពាល់ដល់ជីវិតអាពាហ៍ពិពាហ៍ ក៏ដូចជាមានផលប៉ះពាល់នូវបុគ្គលដែលពាក់ព័ន្ធជាពិសេសគឺកូន។ ប្រាកដណាស់ នៅពេលដែលចំណងអាពាហ៍ពិពាហ៍មួយឈានដល់ដំណាក់កាលនៃការបែងចែកទ្រព្យសម្បត្តិនេះ គឺមានន័យថាចំណងអាពាហ៍ពិពាហ៍នេះត្រូវបានផ្តាច់ដោយមូលហេតុដូចខាងលើ ដែលសហព័ទ្ធត្រូវធ្វើការសម្រេចចិត្តក្នុងការបែងចែកទ្រព្យនេះ។ ទ្រព្យសម្បត្តិ អាចត្រូវបានបែងចែកតាមរយៈវិធីពីរយ៉ាងគឺ តាមការព្រមព្រៀង និងតាមសេចក្តីសម្រេចរបស់តុលាការ។ ដែលចំណុចទាំងនេះនឹងត្រូវបានធ្វើការបកស្រាយដូចខាងក្រោម។

### ២.២.១. ការបែងចែកតាមការព្រមព្រៀងរបស់សហព័ន្ធ

សហព័ទ្ធអាចកំណត់ក្នុងការបែងចែកទ្រព្យសម្បត្តិគ្នា ដោយមានការព្រមព្រៀងពីភាគីទាំងសងខាងបានសេចក្តីថា ភាគីទាំងសងខាងគឺមិនគិតថាភាគីណាម្ខាងបានចំណែកច្រើនជាងខ្លួនឡើយ

[58] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥១។

[59] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥២។

ដោយការបែងចែកនេះ គឺត្រូវធ្វើទៅតាមអ្វីដែលខ្លួនបានព្រមព្រៀងទុកជាមុនរវាងភាគីទាំងសងខាង។ ក្នុងករណីនេះ តុលាការនឹងធ្វើការសម្រេចលើការបែងចែកទ្រព្យសម្បត្តិទៅតាមអ្វីដែលភាគីទាំងសងខាងបានព្រមព្រៀងទុកជាមុននោះ។

ឧទាហរណ៍៖ នៅពេលដែលមានការលែងលះគ្នាកើតមានឡើង ភាគីប្តីសុខចិត្តត្រឹមតែទទួលយកម៉ូតូ និងបានធ្វើការយល់ព្រមជាមួយភាគីម្ខាងទៀតក្នុងការអនុញ្ញាតឲ្យភាគីម្ខាងទៀតទទួលយកនូវឡានដែលជាទ្រព្យសម្បត្តិរួមនោះ។

ប៉ុន្តែក្នុងករណីខ្លះ ការព្រមព្រៀងរបស់សហព័ទ្ធនោះ គឺភ្ជាប់ជាមួយនូវវិការៈតាមរយៈការគម្រាមកំហែងជាដើម ដែលជាហេតុនាំឲ្យការព្រមព្រៀងខាងលើអាចឈានដល់ការលុបចោល។

– ការគម្រាមកំហែងៈ គឺសំដៅទៅលើបុគ្គលដែលបានបង្ហាញឆន្ទៈដោយមានការគម្រាមកំហែងពី សំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន ក្នុងការយល់ព្រមបែងចែកទ្រព្យសម្បត្តិតាមអ្វីដែលគេចង់បាន។ តុលាការអាចធ្វើការលុបចោលនូវកិច្ចសន្យា បានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

ឧទាហរណ៍៖ ភាគីប្តីបានធ្វើការគម្រាមកំហែង ទៅកាន់ភាគី ម្ខាងទៀតដែលជាភាគីប្រពន្ធថានឹងធ្វើការសម្លាប់កូនខ្លួន ប្រសិនបើប្រពន្ធមិនធ្វើការ យល់ព្រមក្នុង ការបែងចែកទ្រព្យសម្បត្តិជាមួយខ្លួនទេនោះ ដូចនេះ ប្រសិនបើគេរកឃើញថាវាមានវិការៈបែបនេះ តុលាការមានសិទ្ធិក្នុងការលុបចោលនូវការព្រមព្រៀងក្នុងការបែងចែកនោះ។

### ២.២.២ ការបែងចែកតាមសេចក្តីសម្រេចរបស់តុលាការ

បើគ្មានការព្រមព្រៀង សហព័ទ្ធម្នាក់ៗត្រូវយកតែទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួនដែលមានមុនរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមរតកក្តី ជាអំណោយក្តី ជាអច្ច័យទានក្តី ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ។[60] ដូចនេះដើម្បីឲ្យការបែងចែកនេះធ្វើឡើងប្រកបដោយភាពងាយស្រួល យើងនឹងធ្វើការបែងចែកទ្រព្យសម្បត្តិតាម ៥ ដំណាក់កាល គឺ៖

[60] ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, មាត្រា ៧០។

- ការសម្គាល់មុខទ្រព្យសម្បត្តិ
- ការចាត់ប្រភេទទ្រព្យសម្បត្តិ
- ការវាយតម្លៃលើទ្រព្យសម្បត្តិ
- ការបែងចែកទ្រព្យសម្បត្តិដោយឡែក
- ការបែងចែកទ្រព្យសម្បត្តិរួម។

**ក. ការសម្គាល់មុខទ្រព្យសម្បត្តិ**

ការសម្គាល់មុខទ្រព្យសម្បត្តិ គឺជាការសម្គាល់លើទ្រព្យសម្បត្តិរបស់សហព័ទ្ធមានន័យថា តើទ្រព្យសម្បត្តិនោះមានអ្វីខ្លះ? ហើយទ្រព្យសម្បត្តិទាំងនោះអាចជាចលនទ្រព្យ ឬ ជាអចលនទ្រព្យ ។ ទ្រព្យដែលសហព័ទ្ធទទួលបាននោះ ក៏អាចជាទ្រព្យរូបី ឬ ទ្រព្យអរូបីផងដែរ។ ទ្រព្យរូបីគឺសំដៅទៅលើទ្រព្យដែលអាចមើលឃើញបាន ឧទាហរណ៍ដូចជា ផ្ទះ រថយន្ត ជាដើម។ ទ្រព្យអរូបីគឺសំដៅដល់ទ្រព្យដែលត្រូវបានបង្កើតឡើងដោយសិទ្ធិ។ ដូចនេះ ការសម្គាល់មុខទ្រព្យសម្បត្តិជាដំណាក់ដំបូងក្នុងការបែងចែកតាមសេចក្តីសម្រេចរបស់តុលាការ។

**ខ. ការចាត់ប្រភេទនៃទ្រព្យសម្បត្តិ**

ដំណាក់កាលបន្ទាប់គឺជាការចាត់ប្រភេទនៃទ្រព្យសម្បត្តិ ដែលការចាត់ប្រភេទនេះគឺធ្វើឡើងក្នុងការកំណត់ថាទ្រព្យសម្បត្តិណាខ្លះជាទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិណាខ្លះជាទ្រព្យសម្បត្តិរួម។ ក្នុងករណីនេះ សហព័ទ្ធទាំងសងខាងត្រូវធ្វើការផ្តល់នូវភស្តុតាង ឬ ការអះអាងស្របច្បាប់ណាមួយថាទ្រព្យសម្បត្តិ ទាំងនេះជាទ្រព្យសម្បត្តិដោយឡែក ឬ ទ្រព្យសម្បត្តិរួម។

បានជាយើងត្រូវតែធ្វើការចាត់ប្រភេទនៃទ្រព្យសម្បត្តិនេះព្រោះ ដើម្បីផ្តល់នូវភាពងាយស្រួលក្នុងការកំណត់ថា ទ្រព្យសម្បត្តិណាដែលត្រូវបែងចែកគ្នា និងទ្រព្យសម្បត្តិណាមិនត្រូវបែងចែក។ ក៏ប៉ុន្តែ ក្នុងករណីខ្លះ ក៏បានធ្វើឲ្យយើងពិតជាពិបាកក្នុងការកំណត់ថាទ្រព្យសម្បត្តិនេះជាទ្រព្យសម្បត្តិដោយឡែក ឬ ទ្រព្យសម្បត្តិរួម។ ឧទាហរណ៍៖ មុនពេលរៀបអាពាហ៍ពិពាហ៍ប្រពន្ធបានទទួលនូវផ្ទះមួយតាមរយៈប្រទានកម្មពីឪពុករបស់ខ្លួន តែផ្ទះនោះមានសភាពចាស់ទ្រុឌទ្រោមខ្លាំងណាស់ ហើយអាចវាយតម្លៃបានថា ផ្ទះនោះមានតម្លៃត្រឹមតែ ១០០០០ ដុល្លាអាមេរិច ប៉ុណ្ណោះ។

តែក្រោយពីរៀបអាពាហ៍ពិពាហ៍ហើយ សហព័ទ្ធទាំងសងខាងបានខិតខំប្រឹងប្រែងក្នុងការកែលំអផ្ទះនោះ ដែលបានធ្វើឲ្យផ្ទះនោះកើតនូវតម្លៃយ៉ាងច្រើនរហូតដល់ ៨០០០០ ដុល្លារអាមេរិច។ ប៉ុន្តែចំណងអាពាហ៍ពិពាហ៍នោះត្រូវបានបញ្ចប់។

ដូចនេះ ផ្ទះដែលជាទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធនោះនឹងត្រូវធ្វើការសម្រេចយ៉ាងណា ប្រសិន បើទ្រព្យសម្បត្តិនោះមានការចូលរួមពីសំណាក់ភាគីប្ដីដូចនេះ? តើវានៅតែជាទ្រព្យសម្បត្តិដោយឡែក ឬ វានឹងក្លាយជាទ្រព្យសម្បត្តិរួមវិញ?

### គ. ការវាយតម្លៃទ្រព្យសម្បត្តិ

ដំណាក់កាលបន្ទាប់ គឺជាការវាយតម្លៃទ្រព្យសម្បត្តិ ដែលមានន័យថាទ្រព្យសម្បត្តិរបស់សហព័ទ្ធត្រូវបានវាយតម្លៃពីអ្នកដែលមានជំនាញ ក្នុងការកំណត់តម្លៃសមស្របមួយទៅលើទ្រព្យសម្បត្តិនោះ។ ហេតុដែលយើងត្រូវការធ្វើការវាយតម្លៃទ្រព្យនេះ គឺព្រោះដើម្បីឲ្យភាគីសហព័ទ្ធទាំងសងខាងទទួលបាននូវចំណែកស្មើគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិនេះ និងជៀសវាងមិនឲ្យមានវិវាទកើតមានឡើងពីសំណាក់ភាគីណាម្ខាង។ ការវាយតម្លៃនេះ គឺត្រូវធ្វើទៅតាមតម្លៃទីផ្សារនាពេលបច្ចុប្បន្នកាល។ ឧទាហរណ៍៖ សហព័ទ្ធមានឡានមួយគ្រឿង និងម៉ូតូមួយគ្រឿង ហើយឡានត្រូវបានប្រគល់ឲ្យភាគីប្ដី ហើយភាគីប្រពន្ធត្រូវបានទទួលត្រឹមតែម៉ូតូ នោះភាគីប្រពន្ធប្រាកដជាមិនសុខចិត្តទេព្រោះជាទូទៅឡានមានតម្លៃថ្លៃជាងម៉ូតូ ដូចនេះវិវាទនឹងកើតមានឡើង។

### ឃ. ការប្រគល់ទ្រព្យសម្បត្តិដោយឡែក

ដំណាក់កាលនេះ ទ្រព្យសម្បត្តិដោយឡែក គឺត្រូវផ្ដល់ជូនឲ្យម្ចាស់ទ្រព្យវិញតាមដែលខ្លួនមានមុនរៀបអាពាហ៍ពិពាហ៍ ក៏ដូចជាទ្រព្យដែលខ្លួនបានទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន ផ្សេងៗ...។

### ង. ការបែងចែកទ្រព្យសម្បត្តិរួម

ដំណាក់កាលចុងក្រោយនេះ គឺជាការបែងចែកទ្រព្យរួមដែលសហព័ទ្ធទទួលបាន។ គួរបញ្ជាក់ថា សហព័ទ្ធអាចធ្វើការបែងចែកទ្រព្យសម្បត្តិរួមនេះបាន លុះត្រាតែមានការព្រមព្រៀងក្នុងការទទួលយកចំណែករបស់ខ្លួនដែលនឹងទទួលបាន។ ក៏ប៉ុន្តែ ប្រសិនការព្រមព្រៀងនេះបានបង្កើត

ឡើង ហើយធ្វើឲ្យមានការជំទាស់ និងមិនសុខចិត្តក្នុងការទទួលយកទ្រព្យសម្បត្តិនោះ នោះទ្រព្យសម្បត្តិនោះ ត្រូវទុកសមត្ថកិច្ចឲ្យទៅតុលាការក្នុងការចាត់ចែងទ្រព្យសម្បត្តិនោះជូនដល់សហព័ទ្ធ។

**ករណីពិសេស៖**

ក្នុងករណីខ្លះ តុលាការអាចធ្វើបែងចែកទ្រព្យសម្បត្តិទៅតាមករណីផ្សេងៗដែលខ្លួនគិតថាជាករណីពិសេស ហើយសមស្របនឹងទទួលយកបាន។

ការបែងចែកតាមករណីពិសេសនេះ មានន័យថាតុលាការមានសិទ្ធិក្នុងការប្រគល់នូវចំណែកដែលបានមកពីការបែងចែកទ្រព្យសម្បត្តិនោះ ទៅភាគីម្ខាងច្រើនជាងភាគីម្ខាងទៀត ដោយសម្អាងលើស្ថានភាពរបស់ភាគីម្ខាងៗកំពុងជួបប្រទះ ឬ នឹងជួបប្រទះ។ ក្នុងការបែងចែកនេះភាគីម្ខាងអាចមានសិទ្ធិក្នុងការទទួលបាននូវ ២/៣ នៃទ្រព្យសម្បត្តិ ឬ បាន ៣/៤ ជាដើម ប្រសិនបើតុលាការបានពិចារណាថាជាករណីពិសេសនេះ។ ការធ្វើការបែងចែកទ្រព្យសម្បត្តិរបស់តុលាការ តាមករណីពិសេសនេះគឺ ធ្វើឡើងដើម្បីឲ្យភាគីនីមួយៗទទួលបាននូវភាពសុខដុមរមនា នាក្រោយពេលលែងលះគ្នា។ ករណីពិសេសនេះអាចមានដូចជា៖

- ផលប្រយោជន៍កូន៖ ដោយហេតុថាក្រោយពីការលែងលះ តុលាការត្រូវធ្វើការកំណត់ពីសមត្ថកិច្ចក្នុងការចិញ្ចឹមបីបាច់ ថែរក្សាកូនឲ្យទៅភាគីម្ខាង ដូចនេះភាគីម្ខាងនេះមានសិទ្ធិក្នុង ស្នើសុំក្នុងការទទួលបាននូវទ្រព្យសម្បត្តិនេះច្រើនជាងភាគីម្ខាងទៀតបាន ដូចសម្អាងថាករណីនេះជាករណីពិសេស។

- ការងារជាមេផ្ទះ៖ គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។ [61] ដូចនេះភាគីប្រពន្ធ ឬ ប្តីដែលបានទទួលរ៉ាប់រងនូវការងារគេហកិច្ចកក្នុងអំឡុងអាពាហ៍ពិពាហ៍នេះ គឺមានសិទ្ធិក្នុងការស្នើសុំទាមទារក្នុងការទទួលបាននូវទ្រព្យសម្បត្តិច្រើនជាងភាគីម្ខាងទៀតបាន។

- អាយុ និងស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត៖ ប្រសិនបើសហព័ទ្ធណាម្ខាងមានវ័យចំណាស់ជាង និង មានស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត មានសភាពមិនល្អ ឬ មានភាពទ្រុឌទ្រោមនោះវាក៏ជាកត្តាមួយដែលនាំឲ្យមានការបែងចែកនេះកើតឡើងផងដែរ។

[61] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០។

- លទ្ធភាពការងាររបស់ភាគី៖ ប្រសិនបើលទ្ធភាពការងាររបស់សហព័ទ្ធម្ខាងមានសភាពល្អប្រសើរខ្លាំង ហើយភាគីម្ខាងទៀតមានលទ្ធភាពក្នុងការរកចំណូលតិចតួចប៉ុណ្ណោះ ដូចនេះ តុលាការក៏អាចសម្រេចយកនូវគោលការណ៍នេះមកប្រើ ដើម្បីឲ្យភាគីដែលទទួលបានចំណូលតិច នោះទទួលបានទ្រព្យសម្បត្តិច្រើនជាងភាគីម្ខាងទៀត។ ដោយផ្អែកតាមមូលហេតុថា ការបាត់បង់របស់ភាគីដែលរកចំណូលបានខ្ពស់នោះ គឺមានសមភាពងាយស្រួលក្នុងការទទួលបាននូវទ្រព្យសម្បត្តិនោះវិញ ផ្ទុយពីភាគីដែលរកចំណូលបានតិច។

- ការថែរក្សាទ្រព្យសម្បត្តិ និងការបង្កើនទ្រព្យសម្បត្តិ៖ ប្រសិនបើភាគីណាម្ខាងមិនបានចូលរួមក្នុង ការថែរក្សាទ្រព្យសម្បត្តិ ហើយបានប្រើប្រាស់ទ្រព្យសម្បត្តិនោះខ្ជះខ្ជាយក្នុងពេលចំណងអាពាហ៍ពិពាហ៍ នោះតុលាការក៏អាចសម្រេចថាវាជាករណីពិសេសផងដែរ។

កត្តាទាំងអស់ខាងលើនេះ សុទ្ធតែជាការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធ ក្រោយពីពេលចំណងអាពាហ៍ពិពាហ៍មួយត្រូវបានបញ្ចប់។ សហព័ទ្ធទាំងអស់មានសិទ្ធិសេរីភាព ជ្រើសរើសយកវិធីណាមួយក្នុងចំណោមខាងលើ មកធ្វើបែងចែកទ្រព្យសម្បត្តិរបស់ខ្លួន។

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការបកស្រាយខ្លឹមសារខាងលើនេះ យើងអាចសម្គាល់បានថា ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ នឹងត្រូវកើតមាននៅពេលដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់មួយកើតមានឡើង។ សហព័ទ្ធទាំងសងខាងអាចធ្វើការជ្រើសរើសប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា ឬ ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់។

ជាទូទៅ ប្រជាពលរដ្ឋតែងតែមិនសូវយកចិត្តទុកដាក់ពីការកំណត់សមត្ថកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនេះប៉ុន្មានទេ ដោយខ្លួនតែងគិតថាទ្រព្យសម្បត្តិរបស់ពួកគេដែលមានមុនពេលអាពាហ៍ពិពាហ៍ក្តី ឬ អំឡុងពេលអាពាហ៍ពិពាហ៍ក្តី គឺសុទ្ធសឹងតែជាទ្រព្យសម្បត្តិរួម ដែលសហព័ទ្ធណាម្ខាងក៏មានសិទ្ធិក្នុងការធ្វើការប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងដែរ។ ការយល់ឃើញបែបនេះហើយ ទើបនាំឲ្យសហព័ទ្ធខិលខូចមួយចំនួនចាប់យកឱកាសនេះ ក្នុងការធ្វើការទាញយកផលប្រយោជន៍លើទ្រព្យសម្បត្តិនេះ ដែលជាហេតុនាំឲ្យសហព័ទ្ធម្ខាងទៀតទទួលរងនូវការខូចប្រយោជន៍។ ហេតុនេះហើយទើបរាជរដ្ឋាភិបាលបានធ្វើការបង្កើតនូវច្បាប់ស្តីពីប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា និងប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់កំណត់នេះឡើង ក្នុងបំណងធ្វើការកំណត់នូវសិទ្ធិរបស់សហព័ទ្ធ ក៏ដូចជាធ្វើការការពារនូវផលប្រយោជន៍របស់សហព័ទ្ធទាំងសងខាងលើការគ្រប់គ្រងទ្រព្យសម្បត្តិ។ ប្រព័ទ្ធទាំងនេះក៏បានចូលរួមជាដំណោះស្រាយក្នុងការកាត់បន្ថយ ការការពារ និងទប់ស្កាត់នូវវិវាទដែលអាចបង្កឡើងតាមរយៈប្តី ឬ ប្រពន្ធលើបញ្ហានៃការគ្រប់គ្រងទ្រព្យសម្បត្តិនេះ។ ប្រព័ទ្ធទាំងពីរនេះត្រូវបានចែងនូវគោលការណ៍យ៉ាងច្បាស់លាស់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ សម្រាប់បែងចែកសមត្ថកិច្ចរបស់សហព័ទ្ធ លើទ្រព្យសម្បត្តិ ក៏ដូចជាប្រភេទនៃទ្រព្យសម្បត្តិដែលសហព័ទ្ធមានសិទ្ធិក្នុងការគ្រប់គ្រងប្រើប្រាស់ និងចាត់ចែង ។

ស្របជាមួយគ្នានេះដែល យើងបានដឹងហើយថាប្រទេសយើងជាប្រទេសមួយដែលកំពុងធ្វើការអភិវឌ្ឍន៍ ដែលនាំឲ្យប្រជាជនភាគច្រើនមិនទាន់យល់នូវអំពីប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិនេះទេ ហើយខ្វះខាតក្នុងការទទួលយកនូវចំណេះដឹងពីបញ្ហាការគ្រប់គ្រងទ្រព្យសម្បត្តិនេះ។ មួយវិញទៀត ប្រព័ទ្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺជាប្រព័ន្ធមួយថ្មីសម្រាប់ប្រទេស

កម្ពុជាយើង ដូចនេះហើយប្រជាជនភាគច្រើនគឺមិនត្រូវបានយល់ដឹងពីសកម្មភាពទាំងនេះទេ ដែលជាហេតុនាំ ឲ្យមានវិវាទនៅតែបន្តកើតមានឡើង។

ដូច្នេះហើយដើម្បីបញ្ចៀសបញ្ហាទាំងអស់នេះ រាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចគប្បី ធ្វើការផ្សព្វផ្សាយពីប្រព័ន្ធទាំងពីរនេះជូនដល់ប្រជាពលរដ្ឋ ដើម្បីឲ្យប្រជាពលរដ្ឋឲ្យយល់ដឹងពីបញ្ហា នេះ និងគេចផុតពីការខូចប្រយោជន៍ពីការគ្រប់គ្រងទ្រព្យសម្បត្តិនេះតទៅទៀត។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ, លេខ ៥៦ ក្រ, ២០ កក្កដា១៩៨៩។

ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១ កយ.ស្រក/១៣, ០៩ សីហា ២០១៣។


## សៀវភៅ


គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការប្រចាំក្រសួងយុត្តិធម៌ជំនាញការផ្នែកច្បាប់ អ៊ីសូអ៊ី មីហា. ២០១៤. *កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ*។

រស់ ស៊ីសុវណ្ណា. *នីតិរដ្ឋប្បវេណី*។

ស្រី វណ្ណធី. ២០១២. *នីតិបេតិកភ័ណ្ឌគ្រួសារ*។

ឥន យឿន. ២០១៣. *នីតិគ្រួសារ និង អាពាហ៍ពិពាហ៍*. ភាគ១។

ឥន យឿន. ២០១៣. *នីតិគ្រួសារ និង អាពាហ៍ពិពាហ៍*. ភាគ២។

# ឧបសម្ព័ន្ធ